ម៉ែ ខាត

# ...រស់ព្រោះហ៊ានស្លាប់



ឆាកប្រយុទ្ធ ខ្មែរ-យួន នៅកម្ពុជាក្រោមក្នុងឆ្នាំ ១៩៤៥-៤៦

ឯកសារដែលគេកម្រជួបប្រទះ

# 'គួរឲ្យប្រេះមោចក្នុងចិត្តណាស់ កាលបើឃើញភូមិមានឈ្មោះជាខ្មែរ ហើយបែរពុំមែនជារបស់ខ្មែរនៅវិញ...'



គ្រួសារខ្មែរមួយគ្រួសារនៅខេត្តឃ្លាំង (កន្លែងកើតហេតុ)
'ក្លាយទៅជាយួនបន្តិចម្តងៗ...'

បណ្ណាគារ នគរធំ

តំលៃ ៤០ រៀល

## ម៉ៃខាត់

# រស់...
# ព្រោះហ៊ានស្លាប់

ការផ្សាយរបស់ នគរធំ

ចំនួន ៣ ០០០ ក្បាល

ព.ស. ២៥១៦ គ.ស. ១៩៧២

# អារម្ភកថា

●● *អត្ថបទដែលមានចំណងជើងថា : ...រស់ព្រោះហ៊ានស្លាប់ នេះរៀបរៀងឡើងពុំមែនដោយមានបំណង ចង់ឲ្យបានការប្រទូស្តរ៉ាយរវាង ខ្មែរ និង យួន ដែលកំពុងរីកចំរើនមិត្តភាពជាមួយគ្នាក្នុងគ្រាអាសន្ននេះទេ ។ ក៏ប៉ុន្តែផ្ទុយទៅវិញ ចង់បង្ហាញនូវអ្វី ដែលអាចនាំឲ្យយើង បែកបាក់គ្នា អ្វីដែលយើងត្រូវវាង - ត្រូវជៀស - ត្រូវមានការអត់អោនគ្នាជាភាគី ។ អ្វីដែលយើងត្រូវធ្វើសហប្រតិបត្តិការដោយស្មោះ ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ។*

*ខ្មែរយើងតែងយកពុរាណភាសិតមួយប្រាប់ក - ទូន្មានកូនចៅថា :* «ផ្សែងពួតជាពុំ អាកថ្កុំ កេះជាភ្លើង»: *មនុស្សម្នាក់អាចកប្បាំង ធ្វើបាប*

មនុស្សម្នាក់ទៀត ទោះនៅក្នុងសភាពជាផ្សេងក៏ដោយ ក៏អាចធ្វើឲ្យមនុស្សឡាយនោះថប់ ហើយទំនើបប្រះជាតឬជាតិ ។ មនុស្សយើងធ្លាប់ជកផ្ញើមតាមនេប្រចុះ បើគេខ្ទប់នេមួយ ទំជកតាមនេមួយទៀត បើគេបិទនេទាំងពីរ ក៏ទំព្រជេរកខ្យល់ចេញ–ចូលតាមមាត់ កាលណាគេខ្ទប់នេប្រចុះទាំងពីរ ផែមទាំងខ្ទប់មាត់ទៀត មនុស្សនោះតែងតែត្រជេរ ដើម្បីជៀសសេចក្តីស្លាប់ដោយសាររស់ខ្យល់ជកជាស្វ័យប្រវត្តិ ។ យ៉ាងណាមិញ រឿងពិតដែលកើតឡើងនៅក្នុងឆ្នាំ ១៩៤៥ និងដើមឆ្នាំ ១៩៤៦ នៅកម្ពុជាក្រោម ក្នុងដែនដីសណ្ត ជាពិសេសក្នុងខែត្រឃ្លាំង និងភូមិកោះប្រហាត ក្នុងខែត្រពលលាវ ដែលរស់លោកអ្នកកំពុងមាននេះ ក៏មានលំនាំដូចការរៀបរៀបខាងលើនេះដែរ ។

ជាសំណាងល្អកាលនោះ ក្រោយពីការកាប់សម្លាប់គ្នាមក ខ្មែរ និង យួន បែរជានិយាយស្តាប់គ្នាបានទាន់វេលា បានជាកត្តានាំឲ្យខ្មែរនិងយួននៅទីនោះ បែរមករួបរស់ជាមួយគ្នា ដោយសុខសាន្តវិញដូចដើម ។

យើងចង់បញ្ជាក់ជាថ្មីថា ជាតិសាសន៍ណា ដែលគ្មានអ្វីជាទីពឹងក្រៅពីពឹងលើខ្លួនឯង ឲ្យតែចេះនិយាយស្ដាប់គ្នាបាន - ចេះរួបរួមគ្នា - ចេះរក្សាអាថ៌កំបាំង-ចេះស្ដាប់មេ ស្ដាប់ចៅ មានវិន័យខ្ជាប់ខ្ជួន ចេះស្លាប់ ហើយហ៊ានស្លាប់ ជាតិសាសន៍នោះប្រាកដជាមិនស្លាប់ ។

បញ្ជាក់ : អត្ថបទនេះកើតឡើងដោយមានជំនួយពី :

* ព្រះតេជគុណព្រះធម្មវង្សា ឡូវ ប៊ុយ មេគណៈមហានិកាយ គង់នៅវត្តឧណ្ណាលោម

* លោក វរសេនីយត្រី ណៃ ណាក នាយសេនាធិការដ្ឋាន កងពលថ្មើរជើងទី ៨

* លោកតា ឡូវ សោម នៅពោធិសាត់

ដោយសារថា កាលនោះ ព្រះសង្ឃនិងអស់លោកទាំងនោះនៅជាសាក្សីនៅនឹងកន្លែង ព្រមទាំងបានពីលោកតា ឡូវ គៀង ដែលលោកធ្វើដំណើរមកជុំពេញ មួយផងមួយកាល ។

● ● ● ●

* យុវជន ស៊ាង ដែលនាំយុទ្ធជនស្ទុះចូលទៅរកខ្មាំងដែលកំពុងបាញ់ចំរុះបកដូចទឹកភ្លៀង ។
* យុវជន ចាច់ វង់ «ក្មួយលោកគ្រូចៅអធិការវត្ត» ត្រូវរបួស ហើយត្រូវខ្មាំងអូសទៅរាក យើងរត់ទៅជួយមិនទាន់ ។
* យុវជន ២ នាក់ ដែលត្រូវខ្មាំងសម្លាប់ពេលដើរកាត់តំបន់ខ្មាំងទៅពីរូបនេត្ត ។
* យុវជន ឡាំ តុន ដែលពរកូនត្រូវគ្រាប់ សាងឈាមឲ្យកូន រហូតដល់ស្លាប់ទាំងខ្លួន ស្លាប់ទាំងកូន ។
* យុវជន ឡាំ គីម ដែលត្រូវរបួស ហើយទំតស៊ូរហូតខ្មាំងបាញ់ផ្តាច់ជីវិត ។
– សឹង តាំង ដែលបានដេញពោកគ្រាប់បែក «ស៊ីប៊ីង់តី» ទៅលើខ្មាំង ក្រោយពីក្រុមវាត្រូវបង្ខំឲ្យបោះបង់ភូក រហូតដល់ខ្មាំងបាញ់ស្លាប់ ។

ព្រមទាំងគោរពចំពោះវិញ្ញាណក្ខន្ធបង-ប្អូន-ស្រី ប្រុស-ចាស់-ក្មេង ដែលបានបាត់បង់ជីវិត នៅក្នុងភាគប្រយុទ្ធនៅ ភូនភ្លុក-ដងក្តោង-ផ្តៅពេន-ព្រែកចាក-ស្ទឹងពោធិ-អណ្តូងទឹក-ទួលតាង-ផ្សារតាសេក-ចាក់ខ្ទឹង-បឹងស្បៀក-បឹង

អក្សរ ។ល។ ក្នុងខេត្តឃ្លាំង ដើម្បីជាតិ សាសន៍ ដើម្បី សេរីភាព ដើម្បីឯកភាព ។ និងដើម្បីសំដែងសេចក្តីពិចាប់ ផល់មក-អ្នកខ្មែរជាច្រើន ទៅក្នុងព្រៃភ្នំ និងភូមិដទៃ ទៀត ខេត្តពលលាវ ដែលត្រូវគេបញ្ជាក់ឲ្យចូល ឥន្ទ្រកស្រូវកប៉ុន ហើយដុតសម្លាប់ ដោយយកលេសថា យកទៅរៀន ឬ ទៅទទួលលោភគំ ។

កិច្ចតស៊ូរបស់អស់លោក គឺជាកិច្ចតស៊ូដែលជាតិមាន អាយុគប់ គេតែងប្រកាន់យក ជាកិច្ចតស៊ូដែលគេត្រូវតែ គោរព ។

ដូចនេះ អស់លោក អ្នក ដែលបានចាកពិភពនេះទៅ កាន់ភពថ្មី ប្រកបដោយការស្ងប់ស្ងៀមនេះ សូមអស់លោក ស្គាល់តែបរមសុខតរៀងទៅ អស់កប្ប អស់កល្ប ។

# ឧទ្ទិស

*ពេលដែលខ្ញុំចាប់ផ្ដើមរៀបរៀងអត្ថបទ «...រស់ព្រោះហ៊ានស្លាប់នេះ» ខ្ញុំសូមលើកដៃទាំងទ្វេដាក់លើសិរសា ឧទ្ទិសផលវិញ្ញាណក្ខន្ធ ៖*

* *អ្នកម្ដាយដែល ដែលមិនព្រមបញ្ចេញក្ដីនឹក ដែលគាត់មានចំពោះខ្ញុំ ពេលដែលគាត់បានដឹងថា ខ្ញុំទទួលភារៈដឹកនាំការតស៊ូនៅកម្ពុជាក្រោម ។*
* *លោកតា ថាច់ ហ៊ុម អាយុ ៥០ ប្លាយឆ្នាំ ដែលបានលះបង់ឋានៈគាត់ជាអាចារ្យ មករួមប្រយុទ្ធជាមួយយើង ។*
* *លោក ឡាំ ណុប អាយុ ៥០ ឆ្នាំប្លាយ ដែលបានលើទង់ជាតិខ្មែរជាដំបូងបំផុតលើមុខទ័ព ឆ្ពោះទៅរកខ្មាំង ។*

# ជីដោយ ផាត់



*ពលទោ ម៉ៃ ផាត់ ថតនៅបាត់ដំបង (ទោសុក)*
*កាលពី ឆ្នាំ ១៩៣៨*

*** ខ្ញុំ ម៉ៃ ខាត់ នាមដើម ម៉ៃ ជាត់ ។ សរសេរដោយអក្សរឡាតាំង Mai Khach ត្រូវអានថា ម៉ៃ ខាច់ ដូច្នេះ គ្រួសារខ្ញុំ ស្គាល់ខ្ញុំថា ជាត់ យួនហៅខ្ញុំតាមអក្សរគេថា ខាត់ ចិនហៅខ្ញុំ ប៊ួយ ទិ បារាំងហៅខ្ញុំ កាត្យ «កីឡាចំបាប់ម៉្យាង» ។ អ្នកវង្គការអានឈ្មោះខ្ញុំ ខាច់ ។ នៅឯស្រុកកំណើតកម្ពុជាក្រោម គេស្គាល់ខ្ញុំជា *ថី សោយ ផាត់* ។ លុះចូលមកបម្រើក្រសួងអភិវឌ្ឍន៍សហគមន៍ ខ្ញុំបានទទួលឈ្មោះមួយទៀតប្រកបដោយប្រិយភាព គឺលោកតា ខាត់ ។

រីឯខ្លួនឯងវិញ ខ្ញុំទំប្រាប់គេ-ឯងថាខ្ញុំឈ្មោះ ខាត់ ពីព្រោះមិនចង់ឲ្យគេហៅឈ្មោះខ្ញុំតាមសំបុត្រកំណើត ដែលសរសេរឈ្មោះខ្ញុំខុស ជាត់ ជា ខាត់ ឆិន ខាត់ ផា ខាច់ នោះទេ ។

កុមារ ខាត់ កើតនៅថ្ងៃ ២៣-១១-១៩១១ ខុសត្រូវគ្នាពីរឆ្នាំពីសំបុត្រកំណើត ដែលចុះខុសទៅជាថ្ងៃ ២៣-១១-១៩១៣ ។ ដូច្នេះ បើគិតមកដល់ថ្ងៃសរសេរអត្ថបទ នេះ

ខ្ញុំត្រូវមានអាយុ ៦០ ឆ្នាំ ២ ខែ ២៨ ថ្ងៃហើយ មិនមែន ៥៨ ឆ្នាំទេ ។ ខ្ញុំកើតនៅភូមិផ្តៅកំបុត សង្កាត់ព្រែកតយ ស្រុកអណ្តូងទឹក ខេត្តឃ្លាំង ។

គ្រួសារខ្ញុំ ជាកសិករមានអំបូរជាខ្មែរអ្នកជា ជាអ្នកមានធនធានមធ្យម ។ គ្រួសារខ្ញុំជាគ្រួសារស្លូតបូត ប្រកបដោយសប្បុរសធម៌ទូលំទូលាយណាស់ ។ បានកសាងព្រះវិហារ កុដិ សាលា ក្នុងវត្តពោធិព្រឹក្ស និងស្ពានក្បែរវត្តនោះនៅគង់វង្សរហូតសព្វថ្ងៃ ។ បានចំណាយដីស្រែផ្ទាល់ខ្លួនមួយចំនួន សម្រាប់ធ្វើជាទ្រព្យគរុភណ្ឌ និងជូនដីភូមិបណ្តោយមួយពាន់ម៉ែត្រថ្វាយ សម្រាប់អ្នកទីទ័លក្រសង់ផ្ទះនៅរហូតសព្វថ្ងៃដោយឥតយកឈ្នួល ។

ជីដូន-ជីតា-ឪពុក-ម្តាយខ្ញុំ គាត់មិនស្អប់ទេអ្នកមាន តែច្រើនរាប់រកអ្នកក្រជាង ហើយស្រឡាញ់អ្នកចេះដឹង ។ ប្រហែលជាដោយសារហេតុចុងក្រោយនេះហើយ បានជាលោកចំណាយធនធានឱ្យខ្ញុំមក «ស៊ីរៀន» នៅភ្នំពេញចាប់តាំងពីថ្ងៃ១៣ មេសា ១៩២០ «ខ្ញុំអាយុ៩ឆ្នាំ» ។

អភ័ព្វណាស់ ខ្ញុំរៀនស្រះអ ស្រះអា នៅស្រុកកំណើត រៀនអា បេ នៅភ្នំពេញ ទៅប្រឡងចូលកូលេសនៅស្រុកយួន ។ មកដល់ត្រឹមនេះ ខ្ញុំមានជំនឿថា អស់លោកអ្នកអាន អាចសន្និដ្ឋានបានថា ខ្ញុំមានការចេះដឹងដល់ណា ។

ខ្ញុំខូចចិត្តណាស់ ដោយបំពេញបំណងជូនមាតា-បិតា មិនបានដូចចំណង់របស់លោក ប៉ុន្តែលោកមានធម៌មេត្តា ចំពោះខ្ញុំជានិច្ច ព្រោះលោកជាមនុស្សជឿធម៌ ជឿអាថ៌ ដោយលោកបានបញ្ជាក់មកខ្ញុំវិញថា « ឯង គ្មានធម៌បុព្វ ដូចគេ » ។

ក្នុងឆ្នាំ ១៩៣៤ ក្នុងភាពខ្ញុំជាមនុស្សម្នាក់មានព្រលឹង តែទៅលើការកសាងកុសល ក៏ក្លាយទៅជាយុវជនស្ម័គ្រចិត្តម្នាក់ ទទួលបៀរត្យប្រចាំខែ ៣រៀល ៤កាក់កន្លះ ។ នេះជាផលវិបាក គ្រួសារមួយដែលខ្ញុំជាមនុស្សចិត្តធម៌ ទៅជាមនុស្សរៀនកាប់ចាក់បាន ។

ចាប់តាំងពីឆ្នាំ១៩៣៤ មក ខ្ញុំដែលធ្លាប់តែធ្វើអំពើល្អ ធ្លាប់តែឮពាក្យទូន្មានឲ្យដើរ ផ្លូវត្រង់ ផ្លូវត្រូវ តួយ៉ាងដូចជា លោកតាខ្វាត តែត ខ្ញុំ ដែលអ្នកផងទទួលស្គាល់ថាគាត់មាន លក្ខណៈជាអ្នកដឹកនាំ ហើយមាននាទីជា ឧត្តមប្រឹក្សារបស់ រដ្ឋការខេត្តយួនផង គាត់តែងទូន្មានខ្ញុំថាៈ កើតមកជាមនុស្ស បើមិនបានធ្វើល្អ កុំតែប្រព្រឹត្តអាក្រក់-បើមិនបានធ្វើបុណ្យ កុំតែសាងបាប ធ្វើឲ្យគេទឹកភ្នែក ជៀសវាងមិនរួចតែពេល មានសង្គ្រាមឯណោះសោះ ក៏ខ្លួនខ្ញុំក្លាយទៅជាអ្នករៀនតែ បាញ់ ប្រយុទ្ធ ដោយកាំបិត-ចំពុះទុង-រៀនតែបច្ចេកទេស ខាងសម្លាប់សត្រូវ ។

ក្រោយពីបានចូលរៀនក្នុងសាលា យោធានានា នៅក្រុងព្រៃនគរ នៅទួលតាមោគនៅអ្នកាប់មក ខ្ញុំបានទទួលសញ្ញាប័ត្រ ប្រើវើដីសេហ្វដីសិចស៊ីយ៉ុង ក្នុងឆ្នាំ ១៩៣៧ដែលមានពិន្ទុរហូតដល់ទៅ ១៨,៣៤ ក្រោយមកបានបំពេញវិជ្ជាផ្នែកវិជ្ជាយុទ្ធសាស្ត្រអនុវត្តិប្រឡងចេញជាប់លេខ ១ ឆ្នាំ ១៩៤១ ខ្ញុំធ្វើជាគ្រូបង្ហាត់វិជ្ជាយុទ្ធសាស្ត្រនៅទួលតាមោគ «កម្ពុជាក្រោម» ។ ក្រោយមក ខ្ញុំបានច្បាំងនឹងសៀម និងជប៉ុន និងយៀកមិញ ។ ឧត្តមសេនិយ៍ហាវឈ្មោះ ត្រឹង យ៉ុង ស្វាយ ហៅ ណាំលៀ បានឲ្យគេតាមសម្លាប់ខ្ញុំ ។ ខ្ញុំក្រឡាប់ឡាន ៣ ដង បាក់ស្មារទាំងពីរ ។ ខ្ញុំត្រូវរបួសពេលប្រយុទ្ធនៅហាវទៀត ។

នៅយប់ ៩ មីនា ១៩៤៥ ខ្ញុំត្រូវជប៉ុនចាក់នឹងចំពុះទុង តាមប្រហោងទ្វារដែក ប៉ុន្តែជាសំណាងល្អ ខ្ញុំគេចផុត ។

ព្រលឹមថ្ងៃ ១០ មីនា ១៩៤៥ ខ្ញុំប្តូរស្លាប់ដើម្បីយកចៅហ្វាយចាស់ដែលបរាជ័យ ទៅលាក់នៅភូមិចាម ហៅភូមិ ចូវយ៉ាង ក្នុងស្រុកមាត់ជ្រូក ។ រសៀលថ្ងៃ ១០ មីនា ១៩៤៥ ខ្ញុំត្រូវជាប់គុកជប៉ុន ។ ពេលយប់ខ្ញុំគេចរត់រួចទៅលាក់ខ្លួនក្នុងទ្រុងពពែនៅផ្ទះយួន ដែលខ្ញុំស្គាល់នៅជិតផ្សារទាងលើ ។ ព្រឹកឡើងយកអីវ៉ាន់បន្តិចបន្តួចនាំគ្រួសារ និង កូនតូចៗ ចូលទូកទៅនៅផ្ទះចាម នៅភូមិ

ស្វាយ ត្រូវចោរលួចអស់ខ្លះ ។

ថ្ងៃ ២០ មីនា ១៩៤៥ យួនដែលខ្ញុំជួលចែវទូកជូនទៅស្រុកកំណើត ប្រាថ្នាចង់សម្លាប់ខ្ញុំដើម្បីយកអីវ៉ាន់ម្តងទៀត ប៉ុន្តែសំណាង បានមិត្តភក្តិដែលទៅជាមួយដឹងទាន់ ។

បារាំងចាញ់ជប៉ុន ខ្ញុំត្រូវអស់លក្ខណ៍ទៅសម្ងំធ្វើស្លូតក្នុងផ្ទះឪពុក-ម្តាយនៅកម្ពុជាក្រោម ។ ខ្ញុំរៀនត្បាញ ចេះរវៃ ចេះទារ ឲ្យបាយអំបោះ ចេះអន្ទង ។ល។

យួនតែកនេះផ្ទះខ្ញុំរករឿង យួនយកខ្ញុំធ្វើជាសត្រូវ ។ ម្ល៉ោះហើយ ខ្ញុំនិងភរិយាខ្ញុំ ដោយញាតិមិត្តជួយផង ទំរស់នៅជាជួយញាតិ មិត្ត ហើយទទួលយកស្រែពីម្តាយ-ឪពុកខ្ញុំធ្វើបានជាង ១.០០០ថាំងបាយក្នុងឆ្នាំនោះ ។

ថ្ងៃ ២ មករា ១៩៤៦ ខ្ញុំត្រូវបង្ខំចិត្តដឹកនាំចលនាតស៊ូនៅកម្ពុជាក្រោម ដែលអ្នកម្ខាងអាងអំណាច អាងមហិទ្ធិឫទ្ធិ អ្នកម្ខាងទៀតគ្មានអ្វីអាងក្រៅពីឆន្ទៈចង់រស់ជាមនុស្សមានសេរីភាពក្រោមពន្លឺយុត្តិធម៌ ។ ជាការប្រយុទ្ធមួយដ៏ខ្លី ប៉ុន្តែសាហាវ ក្រៃណាសាហាវ ដូចខ្ញុំនឹងរៀបរាប់ជូនក្នុងទំព័រខាងក្រោមនេះ ។

ពីរខែក្រោយមក ពេលបារាំងត្រឡប់មកវិញស្រួលបួលហើយ គេឲ្យខ្ញុំធ្វើអភិបាលស្រុក ។ ក្នុងមុខងារថ្មីនេះ ខ្ញុំបានធ្វើការកសាងសន្តិភាព រហូតដល់គួសត្រូវ

និយាយស្តាប់គ្នាបានដូចដើមវិញ ហើយបានរក្សាសន្តិភាព រាប់រកគ្នារហូតសព្វថ្ងៃ ។

ចុងឆ្នាំ ១៩៤៦ ខ្ញុំបានទទួលឋានន្តរសក្តិជា ព្រឹទ្ធបាលទោ ហើយទទួលបញ្ជាឲ្យចូលបម្រើកងទ័ពសម្ព័ន្ធមិត្តនៅក្នុងកងពលលេខ ៤៣ ដែលមានសកម្មភាពនៅក្នុងខេត្តទឹកខ្មៅ ក្នុងមុខងារជាមេបញ្ជាការកងអនុសេនាតូច ដែលមាននាយទាហានវេង និងពលទាហានជាជាតិបារាំងសុទ្ធ ។

ឆ្នាំ ១៩៤៧ ខ្ញុំត្រូវផ្លាស់មកមាត់ជ្រូក ក្រោយមក មកនៅតាកែវ និងកំពត មានឋានន្តរសក្តិជាព្រឹទ្ធបាលឯក បំពេញមុខងារជានាយទាហានខាងបរិក្ខារក្នុង កងវរសេនាតូចនៃកងទ័ពជាតិ ដែលមានវរសេនិយទោ តូម៉ា ជាមេបញ្ជាការ ។

ឆ្នាំ ១៩៤៨ ខ្ញុំចូលមកធ្វើជានាយករងនៃការិយាល័យពត៌មាន នៅសេនាធិការដ្ឋាននៃកងទ័ពសម្ព័ន្ធមិត្តនៅក្រុងភ្នំពេញ ។

ចាប់តាំងពីថ្ងៃ ២៥-១១-១៩៥០ ខ្ញុំធ្វើជាអភិបាលស្រុករមាស-កំពង់លែង ខេត្តកំពង់ឆ្នាំង ស្វាយទៀប-ស្វាយរៀង ខេត្តស្វាយរៀង បន្ទាយមាស-កំពត ខេត្តកំពត និង នៅសួង ខេត្តកំពង់ចាម រហូតដល់ឆ្នាំ ១៩៦៨ ដែលជាថ្ងៃចូលនិវត្តន៍ ។ ក្នុងមុខងារថ្មីដែលខ្ញុំបំរើអស់ ១៨ ឆ្នាំ ខ្ញុំ

បាត់ក៏ក្លាយទៅជាមន្ត្រីរដ្ឋបាលមួយរូប ដែលខិតខំធ្វើការ ហើយប្រមែប្រមូលបងប្អូនយើង ដែលភៀសខ្លួនចូលមករកសង្គមជាតិវិញចំនួន ជាង៥០០ នាក់ ។ ខ្ញុំបានយកចិត្តទុកដាក់ជាពិសេសទៅលើការប្រយុទ្ធជាមួយចំពួកឈ្លានពាន និងរួមដំណើរជាមួយសង្គមខ្មែរឆ្ពោះទៅរកវឌ្ឍនភាព តាមកម្លាំងដែលខ្ញុំធ្វើទៅបាន មានជួយរំដោះបងប្អូនខ្មែរលើឱ្យរួចផុតពីកណ្ដាប់ដៃខ្មាំង នៅឃុំក្បាលទឹក-តាំងថ្កោ-ចាប្រង់ ច្រើនពាន់គ្រួសារក្នុងខេត្តកំពង់ឆ្នាំង ក្នុងឆ្នាំ១៩៥៤ ជាដើម ។ ក្នុងឆ្នាំ ១៩៥៩ ធ្វើជាភូឈួយខេត្តទី ១ នៃខេត្តស្វាយរៀង ។ ក្នុងការប្រឹងប្រែងនេះ ខ្ញុំបានទទួលឥស្សរិយយសការពារជាតិចំនួន ៣ រាប់ទាំងរបស់សាធារណរដ្ឋបារាំងមួយ គ្រឿងផង មេដាយមាស ៧ មេដាយប្រាក់និងសំរិទ្ធ ១០ គ្រឿងទៀត ។ល។

ក្រោយ ១៨ មីនា ១៩៧០ គឺនៅថ្ងៃ១ ខែសីហា១៩៧០ ខ្ញុំបានទទួលឋានន្តរសក្តិជា អនុសេនីយឯក ហើយបានមកបំរើក្រសួងអភិវឌ្ឍន៍សហគមន៍រហូតសព្វថ្ងៃ ក្រោយពីបានចូលបំពេញវិជ្ជានៅបណ្ឌិតសភាយោធានៅក្រុងភ្នំពេញ ។

# ឆាកប្រយុទ្ធ ខ្មែរ.យួន នៅ
# កម្ពុជាក្រោមក្នុងឆ្នាំ១៩៤៥.៤៦

រឿង... រស់ព្រោះហ៊ានស្លាប់នេះ ជាចំណងជើងនៃឆាកប្រយុទ្ធដ៏ខ្លី ប៉ុន្តែឃោរឃៅបំផុត ចាប់ពីថ្ងៃទី ២ មករា ១៩៤៦ អស់កំឡុងពីរខែ រវាងអ្នកអាងអំណាច និងក្រុមមនុស្សដែលមិនព្រមចុះចាញ់ ដោយមិនទាន់បានបង្ហាញនូវវីរភាពដែលគេមាន ។

ឆាកប្រយុទ្ធដើម្បីសេរីភាពនិងយុត្តិធម៌នេះ បានកើតឡើងជាដំបូងនៅក្នុងសង្កាត់ ព្រែកគយ ស្រុកអណ្តូងទឹក ខេត្តឃ្លាំង ក្នុងដែនដីសណ្តនៃទន្លេមេគង្គ នៅកម្ពុជាក្រោម រួចក៏រាលដាលទៅច្រើនខេត្តខ្លះទៀត ។

រឿង...រស់ព្រោះហ៊ានស្លាប់ នឹងបង្ហាញម្តងទៀតនូវកម្លាំងរបស់សង្គមមួយ ដែលចេះរួមគ្នា ចេះស្លាប់គ្នា ជាពិសេសក្នុងការឈមមុខតទល់នឹងសត្រូវ ។

# ផ្នែកភាគ៣

# ភូមិសាស្ត្រនិងមនុស្ស

ខេត្តឃ្លាំង ជាខេត្តមួយដូចខេត្ត ក្រមួនស-ព្រះត្រពាំង-ព្រែកឫស្សី-ពាមបារ៉ាជ-មាត់ជ្រូក-ពលលាវ-អំពូយាទឹកខ្មៅ ។ល។ ដែរ គឺស្ថិតក្នុងដែនដីសណ្ដនៃទន្លេមេគង្គ ។ តាមតាទួតខ្ញុំប្រាប់ថា ខេត្តនេះកាលដើមឡើយនៅក្រោមអាណាព្យាបាលរបស់ខ្មែរនៃខេត្តបន្ទាយមាស «កំពត» ។ ខេត្តឃ្លាំងជាខេត្តមានគមនាគមន៍បរិបូណ៌ តាមទឹកក៏ដូចជាផ្លូវគោក ។ នៅប៉ែកខាងកើតមានមាត់ទន្លេមេគង្គ ដែលហូរចេញជាចំពាម ចេញទៅសមុទ្រ នាំល្បប់ទៅចាក់កើតជាដីថ្មីធំឡើង ៗ រៀងរាល់ឆ្នាំ ។ ដីល្បប់ហូរដល់ណា ដើមឈើដុះដល់នោះ ប្រជាពលរដ្ឋទៅតាំងលំនៅដ្ឋាននៅទីនោះបន្ទាប់បន្តទៅ ។

ពលរដ្ឋនៃខេត្តឃ្លាំង ដែលជាម្ចាស់ដើម មាននៅកុះកររាប់ពាន់នាក់ ក្នុងភូមិនិមួយ ៗ ដែលមានខ្លះ មាន

បណ្តោយរហូតដល់ទៅ ៧ គ.ម.ឆ្ងាយ ដូចជាភូមិផ្លាំកំបុត-ភូមិព្រែកតយ - ភូមិដងក្ដាង - ភូនក្អែក - ដើមពោធិ - ភូមិទិនតាង - កំពង់ឈើទាល - ភូមិដៃនង - ព្រែកចាក - បឹងព្រលិតតានៅ - មាត់គោង - ផ្តៅពេន - ទន្ទេងឯក្បង - ភូមិឯលិច - ភូមិផ្លាកើត ។ល។ (១) ។ លំនៅដ្ឋានច្រើនសង់របៀបបោរាណដោយកាលជំនាន់មុន សព្វថ្ងៃចាប់ផ្ដើមមានផ្ទះថ្មព្រោងព្រាត ។ អ្នកស្រុកដែលនៅជិតមាត់ទឹក គេច្រើនជីកប្រឡាយទឹកខ្វាត់ខ្វែងនៅជុំវិញផ្ទះដើម្បីឲ្យទឹកចូល បានត្រីទទួលទានផង ដាំដើមដូង ដើមចេក លើសាច់ដីលើកនោះផង ។

របររកទទួលទានគឺធ្វើស្រែ និង នេសាទ ។ ដីស្រែនៅគ្រប់ទិសទីលាតសន្ធឹងដាច់កន្ទុយភ្នែក ។ កាលពីជំនាន់ដើម ពលរដ្ឋខ្មែរជាច្រើន សុទ្ធសឹងតែជាម្ចាស់ដីកម្មសិទ្ធិរាប់រយហិកតារៗក្រោយពីរដ្ឋការយៀកណាមធ្វើនយោបាយកែប្រែចំរើនដីមក ម្នាក់ៗមានត្រឹមតែដីដែលខ្លួនប្រកបរបរដោយផ្ទាល់ គឺមានពីមួយ ដល់ ១៥ ហិកតារប៉ុណ្ណោះៗ បងប្អូនយើងនៅស្រុកនោះ ពុំសូវប្រើគោទេ ប៉ុន្តែមានក្របីរាប់ពាន់ រាប់ម៉ឺនក្បាល ។ នៅរដូវស្រែ មានកសិករខ្លះមាន

---

*(១) គួរឲ្យប្រយោជក្នុងចិត្តណាស់ កាលបើឃើញភូមិមានឈ្មោះជាខ្មែរ ហើយបែរជាពុំមែនរបស់ខ្មែរទៅវិញ ។*

មាំស៊ុនភ្នូរ សំរាប់ស៊ីឈ្នួលភ្ជួរដី កសិករភាគច្រើនមាន មធ្យោបាយដឹកនាំផ្ទាល់ជាកាណូតតូច ៗ ឬទូកគគីរ ៗ នៅក្នុងភូមិនិមួយ ៗ គេឃើញមានដើមឫស្សី ពីងពង់ ដើមឈើផ្លែ ដូចជា ដូង ស្វា ស្វាយ ស្វាយចន្ទី ព្រីង ៗ ដើមក្រូច ឬ ធូរេន ត្នោត ពុំសូវមានទេ ៗ ប៉ុន្តែស្រុកនោះសំបូរណ៍ដើមចាក ដែលអ្នកស្រុកដាំតាមមាត់ព្រែកសំរាប់យកស្លឹកប្រក់ផ្ទះ ៗ ត្រីស្រែ ត្រីសមុទ្រ បង្គា ក្តាមសមុទ្រ សំបូរណ៍ហូរហៀរ នៅរដូវបុណ្យភ្ជុំបិណ្ឌ ៗ នៅរដូវប្រាំង ខ្សត់ត្រីស្រែ តែមានត្រីសមុទ្រទទួលទានគ្រប់គ្រាន់ ៗ ហេតុដូចនេះហើយ បានជាគេពុំដែលទទួលទានក្តាមស្រែទេ ៗ ជនណាទទួលទានក្តាមស្រែ គេទុកជាមនុស្សអន់ ដូចជាអ្នកកម្ពុជាកណ្តាលទីមគោញើផ្លូវឆ្នោះដែរ ៗ បើស្រែណាមានក្តាមច្រើនកាត់សន្ទូង គេដាក់ទ្រូយកទៅបុកចោល ៗ សង្គមខ្មែរកម្ពុជាក្រោមភាគច្រើន ជាអ្នកមានចរិយាស្លូតបូត តែទាំងអស់គ្នាសុទ្ធតែមានចិត្តមោះមុតក្លាហាន ជាពុទ្ធមាមិកជន គេរាប់រកគ្នាណាស់ គេឥតចេះផ្ញក្ដីក្ដាំទេ ៗ ការទាស់ទែងខ្វែងគំនិតគ្នា គេច្រើនហៅរកមនុស្សចាស់ឲ្យជួយផ្សះផ្សាសំរុះសំរួល ៗ គេមានគំនិតសហគមន៍ខ្ពង់ខ្ពស់បំផុត ៗ រដូវស្រែ គេយកដៃគ្នា ហើយគេចាប់ផ្តុំជុំគ្នាពីម៉ោង ៤ ភ្លឺជាក្រុមតាមតិច តាមច្រើនទៅជួយកិច្ចការគ្នា រហូតបានសំ

រេច ៗ លុះវិលមកដល់ទីលំនៅវិញរវាងម៉ោង ១០ ព្រឹក គេចាប់ធ្វើកិច្ចការនៅផ្ទះ ដូចជា ត្បាញល្អី កញ្ជើ ឬវេញខ្សែពោរគី គេច្រើនខ្មៀតធ្វើឱ្យពេលវេលាមានតម្លៃរហូតពេលនិទ្រា ៗ រដូវភ្ជួរ រាស់ ស្ទូង ក៏ដូចជារដូវច្រូតកាត់ បោកបែនដៃ ៗ ម្ចាស់ស្រែនិមួយ ៗ បំរើភ្ញៀវដែលទៅជួយកិច្ចការខ្លួនដោយស្រា បារី រីឯម្ហូប និងបង្អែម គេច្រើនចំហុយត្រីប្រៃ ពងទា ឬ ខត្រី ឬសាច់ជ្រូក ជាពិសេស គេច្រើនស្ងោរល្ពៅនិងស្ករស ដែលនៅស្រុកនោះគេនិយមឱ្យឈ្មោះថា ខល្ពៅ ស្រួចលើបាយដំណើប ដូចរបៀបធ្វើចេកខ្ទិះបាយដំណើប នៅកម្ពុជាកណ្តាលដែរ ។

ពេលច្រូតកាត់ ជាពេលសប្បាយ ពីព្រោះមានអ្នកលក់នំ ចំណីគ្រប់បែបយ៉ាងរែកទៅលក់សព្វទិសទី ៗ ក្រោយពីពេលដឹកគ្រាប់ស្រូវដល់ជង្រុកហើយ គេប្រើត្បាល់ជាន់ឬត្បាល់កៀនបុកអង្រែ ៤ ធ្វើជាអង្ករទុកទទួលទានសម្រាប់មួយឆ្នាំ ៗ បន្ទាប់មក គេនេសាទត្រីក្នុងអណ្តូង ដែលគេជីកឱ្យត្រីចូលក្នុងរដូវវស្សា ឬនេសាទរបៀបផ្សេង ៗ ទៀត ដើម្បីធ្វើ ប្រហុក ផ្អក មុំ ទុកទទួលទានគ្រប់គ្រាន់សំរាប់ឆ្នាំនិមួយៗ ។

ពេលសប្បាយគឺពេលចូលឆ្នាំ តែគេឥតចេះល្បែងប្រជាប្រិយទេ បើមានត្រឹមបោកចំបាប់ក្នុងវត្ត ដែលជួន

កាលមានយួនចូលរួមផង ចំពោះវត្តណាដែលនៅជិតផ្សារ ៗ នៅពេលភ្ជុំបិណ្ឌ ចំលាប់ស្រុកនោះគេសែនបីថ្ងៃ ៗ នៅពេលសែនម្ដង ៗ គេតែងធ្វើម្ហូបអាហារប្រណីត ជាពិសេសគេធ្វើទាទីម រួចគេអញ្ជើញញាតិមិត្តជិតខាងមកជួយអបអរសាទរ ៗ ជនជាតិយួន ចិនខ្លះក៏ត្រូវបានអញ្ជើញចូលរួមផង ដែលនៅកន្លែងដែលមានយួន ចិននៅក្បែរ ៗ

បុណ្យកឋិន បុណ្យផ្កា បុណ្យកំសាន្ត ក៏ត្រូវបងប្អូនយើងគោរពធ្វើតែរៀងរាល់ឆ្នាំដែរ ហើយនៅក្នុងពិធីបុណ្យទាននោះ គេឃើញជនជាតិយួនចូលរួមជាពុទ្ធមាមិកជន ឬជាអ្នកលក់ដូរ ៗ សូមជំរាបថាយួន ឬ ចិន ដែលមានអ្នកខ្លះចូលទៅតាំងលំនៅដ្ឋានជាមួយភូមិខ្មែរ ច្រើនតែកាន់ទំនៀមទំលាប់តាមមនុស្សភាគច្រើន រហូតដល់ជឿអារក្សនិងជំនឿឯទៀតដូចខ្មែរ ថែមទាំងនិយាយភាសាខ្មែរទៀតផង ៗ

បងប្អូនយើងនៅកម្ពុជាក្រោមស្រឡាញ់កីឡា ដោយហេតុនេះហើយបានជានៅរដូវប្រាំង គេតែងឃើញយុវជនប្រព្រឹត្តល្បែងបាល់ទាត់នៅតាមវាលស្រែខ្លះ ឬ តាមភូមិដែលឥតមនុស្សនៅ ៗ ការប្រកួតកីឡាធ្វើឡើងរវាងភូមិមួយនិងភូមិមួយទៀត ឬរវាងខ្មែរនិងយួន ឬចិន ៗ

ខេត្តឃ្លាំង-ខេត្តពលលាវ «ខេត្តពីរជាប់គ្នា» ជាខេត្តមានទូកង ច្រើនបំផុត ហើយអ្នកស្រុកនៅនិយមកីឡានេះរហូតសព្វថ្ងៃនៅពេលភ្ជុំបិណ្ឌ ចូលឆ្នាំខ្មែរ បុណ្យកឋិនទាន ឬ ចូលរួមក្នុងពិធីអ្វីមួយ ។

ល្ខោនបាសាក់ជាល្ខោនមានប្រជាប្រិយភាពបំផុត នៅកម្ពុជាក្រោម ពីដើមកាលស្រុកគ្មានចំបាំង គេឃើញមានក្រុមល្ខោនសឹងគ្រប់សង្កាត់ ក្រៅពីនេះមានរបាំយីកេ និងរៀបចំចាប៉ី មានវង់ភ្លេងពិណពាទ្យ ភ្លេងខ្សែសំរាប់កំសាន្តៗ

ក្នុងពិធីអាពាហ៍ពិពាហ៍ បងប្អូនយើងនៅប្រកាន់របៀបបូរាណដោយភាគច្រើន ដូចជាកូនប្រុសពាក់អាវក្រ ហាមសៀកហូលចងក្បិន ស្រីពាក់អាវបំពង់ពណ៌ សក់បួងរបៀបបូរាណ ចងកកន្សែងចាបុច ។ ខ្នើយផ្ទឹមគេច្រើនប្រើខ្នើយមុខបី ដែលពាក្យក្រៅហៅខ្នើយពូថៅ ។ អាពាហ៍ពិពាហ៍ដែលកំណត់ពេលបីថ្ងៃ មានជួនកាលមានធ្វើពិធីបុកលក្ខណ៍ និងពិធីធ្វើផ្ទេញ ។ ម្ហូបអាហារទទួលភ្ញៀវពី ១០ ឆ្នាំមុន គេនៅឃើញមានរបៀបរៀបចំចានម្ហូបមានជាន់បីដាក់លើថាសស្ពាន់ មានជើងបួនរូបគុន ។ សម័យនេះគេរៀបចំទទួលភ្ញៀវតាមរបៀបសម័យដូចគេដូចឯងអស់ទៅហើយ ។

ទឹកចិត្តបងប្អូនយើងនៅកម្ពុជាក្រោម គឺជាទឹកចិត្ត

អ្នកជាតិនិយម ហើយប្រកបដោយវីរភាពផង ៗ ជីតាខ្ញុំ តែងនិទានពីការប្រយុទ្ធរវាង ខ្មែរ-យួន កាលក្នុងសតវត្សទី ១៩ ជាច្រើនលើកនៅវាលស្រែមួយដែលគេហៅថាស្រែ១ ៗ មេទ័ពខ្មែរច្រើនប្រើសេះជាជំនិះ ឯយួនច្រើនប្រើក្របី ៗ ការកាប់សម្លាប់គ្នា ច្រើនតែធ្វើឡើងពីរឿងរំលោភលើដីស្រែ ឬដីភូមិ ៗ គេសុទ្ធតែបានណាត់ពេលជាមុន ៗ

ខ្មែរកម្ពុជាក្រោមទាំងអស់ ថ្វីបើគេបានដឹងថា ដែនដីដែលគេរស់នៅសព្វថ្ងៃនេះ បានធ្លាក់ទៅក្នុងកណ្ដាប់ដៃអ្នកដទៃទៅហើយក្ដី ក៏គេទុកភូមិស្រុករបស់គេ ជារបស់គេផ្ទាល់ដដែល ៗ ដូចនេះសិទ្ធិ សេរីភាព ក្នុងការរស់នៅរបស់គេ ក៏គេត្រូវតែការពារជានិច្ច ៗ ព្រោះហេតុនេះហើយក្រោយពីពេលដែលបារាំងបរាជ័យទៅ ខ្មែរយើងនៅទីនោះ បន្ទាប់ពីគេធ្វើបាបជំពូនខាងផ្លូវចិត្ត បន្ទាប់មកមានការប្រាថ្នាធ្វើការបង្ក្រាបមក ក៏បានរួមកម្លាំងសាមគ្គីដែលគេបានរក្សាទុកពីយូរយារមកហើយនោះមកប្រើដើម្បីរកសេរីភាពមកវិញ នៅចុងឆ្នាំ ១៩៤៥ ដើមឆ្នាំ ១៩៤៦ ៗ ការតស៊ូរបស់បងប្អូនយើងកាលនោះមានសភាពជាអន្តរកប្ប ពីព្រោះកងកម្លាំងសម្រាប់រក្សាការរៀបរយក៏គ្មាន មន្ត្រីរដ្ឋការឬមន្ត្រីឃុំ ឬភូមិបានភៀសខ្លួនចោលមុខងាររបស់ខ្លួនអស់ ពោលគឺការសំរេចវិញមនុស្សស្លាប់ឬរស់នៅលើដៃអ្នកខ្លាំងពូកែប៉ុណ្ណោះ ៗ

# កំលាំងពួកជាតិ
# ក្នុងឈានជាស្ងៀម

ក្នុងឆ្នាំ ១៩៤៥ ជាពិសេសចាប់តាំងពីថ្ងៃទី ៩ មីនា ទៅដល់ដើមឆ្នាំ ១៩៤៦ ស្ថានភាពនៅឧបទ្វីបឥណ្ឌូចិនទាំងមូលមានការប្រែប្រួលក្រឡាប់ចាក់សំបើមណាស់ ។ ចំពោះអាណានិគមបារាំងចាញ់ជប៉ុន ត្រូវជប៉ុនចាប់ជាឈ្លើយ ។ អ្នករដ្ឋការ ជាពិសេសរាប់ទាំងកងទ័ព និងអ្នកបំរើផលប្រយោជន៍បារាំងក៏ត្រូវជប៉ុនចាប់ដាក់ពន្ធនាគារ ឬ ធ្វើបាប ។ លុះមកដល់ដើមឆ្នាំ ១៩៤៦ ចំពោះសម្ពន្ធមិត្តឈ្នះជប៉ុនម្ដងវិញ ភាពក្រឡាប់ចាក់ក៏មានឡើងទៀត ។ អ្នកដែលមានការទាក់ទងជាមួយជប៉ុន ទោះខាងផ្លូវនយោបាយ ក៏ដូចក្នុងវិស័យឯទៀត ព្រមទាំងអ្នកស្នេហាជាតិខ្លះទៀតត្រូវទទួលបាបគ្រោះពីបារាំងវិញម្ដង ។

ប៉ុន្តែអ្វីដែលជាប្រភពនៃវិនាសកម្ម តាំងពីជំនាន់នោះរហូតមកសព្វថ្ងៃ គឺចលនានៃយួនវៀតមិញ ។ ចលនា

គស្ដីរបស់ជនជាតិយៀកណាម ចំពោះអាណានិគមបារាំងនោះ ពិតមែនតែមានកើតឡើងតាំងពីយូរយារណាស់មកហើយក្ដី ក៏ចលនានេះទើបតែនឹងមានបញ្ចេញសកម្មភាពខ្លាំងឡើង ៗ ចាប់តាំងពីមានការប្រែប្រួលដូចជម្រាបខាងលើ ។

គឺហេតុនេះហើយ បានជាក្រោយពីបារាំងចាញ់ជប៉ុនទៅ ពលរដ្ឋយួន ត្រូវធ្វើការហ្វឹកហ្វឺនវិជ្ជាយុទ្ធសាស្ត្រនៅគ្រប់ព្រៃល្បាក ពោលគឺដូចជានៅក្នុងភូមិព្រៃគគយ ស្រុកអណ្ដូងទឹក ខេត្តឃ្លាំង ។ ចលនាយៀកមិញត្រូវរីកធំធាត់ឡើង ហើយការហ្វឹកហ្វឺនរបស់គេ ក៏កាន់តែមានសន្ទុះស្ទុះឡើងជាលំដាប់ ៗ ក្រោយពីយួនទិញយួនបង្ហាត់គ្នាគេមក បងប្អូនខ្មែរយើងនៅទីនោះ ក៏ដូចជានៅទីដទៃទៀតដែរ ក៏ត្រូវបង្ខំចិត្តចូលហ្វឹកហ្វឺនវិជ្ជាយុទ្ធសាស្ត្រនឹងគេដែរ ។

ចាប់ពីដំបូងដៃមក ខ្មែរយើងចេះតែមានពិភាល់ចំពោះចិត្តថ្មើមរបស់បងប្អូនយួនមកលើយើង ដែលនាំឱ្យយើងខ្វះការកក់ក្ដៅ ហើយដណ្ដឹងសួរខ្លួនឯងថា តើការប្រមូលគ្នាមក ថាមកហ្វឹកហ្វឺននេះដើម្បីគេប្រមូលយើងមកក្រុង ទុកមិនឱ្យយើងចេញទៅណាឆ្ងាយ រកទទួលទានដូចធម្មតា ឬ បានជាមានការពិភាល់ដូចនេះ ពីព្រោះក្នុងការហ្វឹកហាត់គេគ្មានបង្រៀនអ្វីក្រៅពីរៀនដើរ ។ ក្រោយមកហេតុ

ពិតក៏បានលេចចេញអ្នកដំបន្តិចៗ ដែលជាកត្តាមួយជំរុញ ឲ្យខ្មែរមានការត្រិះរិះ

១—មុនដំបូងគេហាមមិនឲ្យកាន់ កាំបិត-ដាវ-ស្ន-លំពែង-ព្រនង់ ដែលយើងមាន ទោះជាឧបករណ៍សំរាប់ធ្វើស្រែក៏ដោយ ។ ក្រោយមកមានកន្លែងខ្លះ គេដើរប្រមូលយករបស់ទាំងនោះតែម្តង ហើយគេទុកតែកាំបិតធ្វើត្រីមួយប្រើប៉ុណ្ណោះ ។

២—ពេលហាត់ដើររាល់ថ្ងៃ ខ្មែរ និងយួន តែងលេងសំដីដាក់គ្នា កើតជាជេរប្រមាថគ្នា ឬដាល់តប់គ្នា ពីព្រោះក្នុងពាក្យជេរប្រមាថរបស់គេ ។ ច្រើនតែជៀលខ្មែរថាដូចនេះ ដូចនោះ ឬ ដូចជាគេថា ខ្មែរឲ្យធ្វើមេភូមិចង់ជំព្រុលផងជាដើម ឬ ក៏គេថា «យួនឆ្កួតប្រហែលខ្មែរអ្នកចេះដឹង» ។

៣—ប្លែកជាងនេះទៅទៀត ពេលហាត់រៀនម្តងៗ ច្រើនតែបញ្ចប់ដោយការវាយតប់គ្នា ពីព្រោះខាងយួន ពេលគេហាត់ដើរមកទន្ទឹមនឹងបងប្អូនយើង គេច្រើនលើកជើងធាក់ខ្មែរពីចម្ងាយ ដោយទៀតយកចង្វាក់ដើរមួយពីរនោះតែម្តង ។

៤—ជួនកាលពេលហាត់រៀនរួចមានចែកអំពិល ដែលសល់អំពីជំនាន់ជប៉ុន គេស៊ីទុកចោល គេឥត

*ឲ្យខ្មែរទេ បើគេឲ្យ គេទុកឲ្យគ្នាគេយកបានស្រេចដាច់សិន បើសល់ទើបបានមកបងប្អូនយើង ។*

*៥–ក្រៅពីកម្ពុជាដឹងច្បាស់លាស់ដូចនេះ ទើបមានការសង្ស័យទៅលើបណ្ដាជនច្រើនខ្លះទៀត ដូចការប្រជុំ គេច្រើនប្រជុំតែជាមួយគ្នាគេ ហើយក្រោយពីការប្រជុំម្ដងៗ តែងមានហេតុភេទផ្សេងៗទៀតកើតឡើង ដូចជាគេឆែកផ្ទះខ្មែរ មានឆែកផ្ទះចិនដោយ ផាត់ រុករើកក្ដារកកាយ ដោយគេថា រកកាំភ្លើងដៃជាដើម ។*

ចំពោះព្រឹត្តិហេតុដូចនេះ យើងតែងតែពិគ្រោះគ្នា ពីព្រោះយើងមានគំនិតមួយជាប់ជានិច្ច គឺយើងមិនព្រមស្លាប់ដោយសារគេខ្ទប់ដង្ហើមយើងជាដាច់ខាត ហើយយើងស្រុះស្រួលគ្នាធ្វើបានសម្រេចដូចតទៅនេះ

*១–រកលេសបំបែកការហ្វឹកហ្វឺនចេញពីយួន យើងធ្វើយ៉ាងនេះ ព្រោះយើងត្រូវរៀនវិជ្ជាយុទ្ធសាស្ត្រយួន ។ ការរៀនដើរយើងមិនត្រូវការហាត់ទៀតទេ មិនតែប៉ុណ្ណោះ យើងមានគ្នាយើងជាអ្នកចេះវិជ្ជាយុទ្ធសាស្ត្របរិបូណ៌ មានកលល្បិចចំពក់ជាដើម យើងលួចបង្រៀនគុនដាវ - គុនដំបងបន្ថែម ព្រោះបងប្អូនយើងខ្លះមានការជំនាញស្រាប់*

យប់យើងធ្វើសមយុទ្ធពីរបៀបការពារភូមិ ពីរបៀបចូលប្រយុទ្ធ ជាពិសេសទៅទៀតយើងធ្វើការដាស់ស្មារតីខ្មែរ ឲ្យមានមនសិការជាតិ ដោយយើងលួចបង្រៀនច្រៀងនគររាជ និងសុវណ្ណភូមិ ។ ក្រោយពីបទពីរនេះយើងឥតចេះអ្វីទៀតទេ គួរឲ្យស្ដាយ ។

២–យើងរៀបចំអាវុធរបស់យើង ដូចជាដាវកាប់ស្មៅ មានកក្រដុក ដែលយើងទំលាក់ទុក យើងចាប់លាវាឲ្យត្រង់វិញ កាំបិតចុងស្រួចដែរតែផងខ្លី យើងផ្លាស់ដាក់ដងវែង ប្រវែងមួយម៉ែត្រញាយ ល្មមប្រើការក្នុងពេលប្រយុទ្ធ យុវជនគេមានកាំបិតស្នៀតគ្រប់គ្នាសម្រាប់ចូលប្រឡូក ។

៣–យើងរៀបចំកន្លែងសម្រាប់លាក់ស្រូវតាមក្រោយផ្ទះនិងជីកកប់ពាងតាមវាលស្រែ ឬក្រោយផ្ទះសម្រាប់លាក់របស់ដូចជា ចាន-ឆ្នាំង-មាស-ប្រាក់-អាវ-ខោ ។ល។

៤–យើងបានដើរកត់អ្នកមានទោចក្រយានទុកសំរាប់ប្រើការ ក្នុងការទាក់ទងរបស់យើងក្នុងពេលមានអាសន្ន និងទោចក្រយានណាចាស់ៗគេលែងប្រើការ ទុកសម្រាប់អារយកបំពង់ធ្វើកាំភ្លើងផង ។

រឿងការដែលរៀបរាប់មកនេះ យើងពុំមានបំណងអ្វីទៅធ្វើការឈ្លានពានជាតិសាសន៍ណាទេ ប៉ុន្តែយើងគ្រាន់តែធ្វើគ្រាប់សត្រូវដេវវិចប៉ុណ្ណោះ ពីព្រោះតាំងពីណាពីណាមក បងប្អូនខ្មែរ និងបងប្អូនយួនតែងរាប់រកគ្នា ខ្មែរនិងយួនមានចងមិត្តភាពជាមួយគ្នា ដែលភាសាជនបទស្រុកនោះគេហៅថា ក្លើ ។ ពេលចូលឆ្នាំយួន-ចិន និងចូលឆ្នាំខ្មែរ មានការអញ្ជើញគ្នាទៅមក មានយួនភាគមិនតិចទៅដែលធ្វើបុណ្យ ធ្វើបាបជួលយើងដែរ ។ ការដែលគេប្រែអាកប្បកិរិយាកាយវិការគេ នៅគ្រាចុងក្រោយនេះ យើងមិនទាន់ច្បាស់ថា គេមានបំណងយ៉ាងណាមកលើយើងទេ ប៉ុន្តែយើងបានប្ដេជ្ញាចិត្តជាស្រេចហើយថា យើងស្លូតមែនតែយើងមិនព្រមស្លាប់ជាដាច់ខាត ។

ថ្ងៃខែ ក៏ចេះតែកន្លងទៅ ព្រឹត្តិការណ៍ជាច្រើនក៏យើងបានឆ្លងកាត់ ប៉ុន្តែថ្ងៃមួយយើងភ្ញាក់នឹងពតិមានដែលលេចចេញមកពីអ្នកនេសាទ ។ អ្នកនោះបានប្រាប់បងប្អូនយើងឲ្យប្រុងប្រយ័ត្ន ពីព្រោះយួននៅវត្តព្រះត្រពាំង ក្នុងភូមិសម្ដេចចាប់ធ្វើបាបខ្មែរ ដោយគេបាននាំគ្នាកៀងចាប់យកក្របីបងប្អូនយើងរាប់រយក្បាលគ្រប់ៗតែម្ដង ម្ល៉ោះហើយមានការកាប់សម្លាប់គ្នាយ៉ាងសាហាវ ។ អ្នកនាំពាក្យមិនបានបញ្ជាក់

អ្វីក្រៅពីនេះទេ ពីព្រោះយើងមិនបានជួបផ្ទាល់ ។ យើងក៏ចាត់គ្នាឱ្យដំណើរដល់បងប្អូនយើងភ្លាម ដើម្បីការពារខ្លួន ប៉ុន្តែសុំកុំឱ្យមានប្រតិកម្មអ្វីឱ្យសោះ។ យើងបានប្រាប់ដល់ភូមិផ្កាគានាវ - កំពង់ឈើទាល - ផងក្ដាង - បឹងព្រលឹត - ភូន ក្អែក ដើមពោធិ៍ អណ្ដូងទឹក ទ្វិនគាង-ផ្កាហៀងជួជាន់ - ដៃធន់ ផ្កាពេន ព្រែកចាក ផ្កាឯលិច ផ្កាឯកើត ផ្កាមាន់គោង ដែលសុទ្ធតែភូមិស្តុកស្តម្ភ មានខ្មែរនៅយ៉ាងកុះករ ឱ្យប្រុងប្រយ័ត្នតែដោយស្ងៀមស្ងាត់ គឺឱ្យ «ដាំដើមគមុខផ្ទះទាំងអស់គ្នា» ។ អ្នកនៅមាត់ព្រែកជាប់ទឹងសមុទ្រ ត្រូវចាត់ការឱ្យយាម ដើម្បីពិនិត្យទូកក្ដោងចេញ-ចូល ។

ប៉ុន្មានថ្ងៃក្រោយមកយើងមានការរន្ធត់ជាខ្លាំង ដោយការពិភាល់របស់យើង បានលេចជារូបរាងច្បាស់ក្រឡែតគឺនៅក្នុងភូមិកោះប្រហាត - យ៉ាវ៉ាយ - ផ្កាអណ្ដែត- ដាំគិន - ដាំយើយ-ព្រែកហ្វូវផុង ឈ្មោះភូមិ ៣ ខាងក្រោយនេះគ្មានឈ្មោះជាខ្មែរទេក្នុងវេត្តកលលរវ យួនបានបញ្ឆោតបងប្អូនយើងប្រុស ៗ ចាយកទៅចូលស្វាគមន៍ «លោកធំ» ឬថាដើម្បីហ្វឹកហ្វឺន ហើយបញ្ចូលក្នុងរោងដាក់ស្រូវរបស់ជប៉ុន ដុតសម្លាប់ទាំងរស់ ចំនួនច្រើនរយនាក់ «គ្រាន់តែអ្នកភូមិផ្កាអណ្ដែតមួយមានដុតស្លាប់ ៤០នាក់» ។

ថ្ងៃបន្ទាប់មកទៀត បិនទៅផ្សារព្រែកគយ ដែលធ្លាប់

មានការទាក់ទងក្នុងមុខរបររកស៊ីជាមួយយើង បានលួចទិញបន្ទិចដីថា យួនវាប្រងបិទផ្លាញវត្តពោធិព្រឹក្សចោលដោយថាវត្តនេះខ្មែរតែងយកធ្វើជាកន្លែងប្រមូលផ្តុំ ៗ តាមគំរោងការសម្ងាត់របស់វា វាមិនមែនដុតវត្តដោយចំពោះទេ តែវាដុតផ្សារដែលនៅជាប់គ្នានឹងកុដិ សាលាខ្លះដែលសង់ក្នុងវត្តនេះ ដើម្បីចម្លងភ្លើងក្នុងវត្ត ៗ

សូមជំរាបបញ្ជាក់អស់លោកអ្នកអានថា តាំងពីដើមទីរហូតដល់ពេលនេះ យើងមិនបានចាំថ្ងៃ-ខែទេ ព្រោះតែស្ថានភាពបងប្អូនយើងកាលនោះ ប្រៀបបានទៅនឹងទូកកណ្តាលទន្លេពីព្រោះម៉ែ ផុះនៅឯភ្នំពេញ អត់បានដឹងទុក្ខរបស់កូនចៅនៅឯនោះសោះ ៗ បារាំង ឬ ជប៉ុនដែលហោចណាស់ ក៏អាចបានជាអាជ្ញាកណ្តាលដែរនោះ យោងតែខ្លួនឯងមិនរួចទៅហើយ តើមានគំនិតឯណាចង់ដឹង ថ្ងៃ-ខែទៅកើត ៗ ម្យ៉ាងទៀត ព្រឹត្តិការណ៍អស់នេះកន្លងទៅអស់រយៈពេល ៦៦ ឆ្នាំទៅហើយ គឺចាប់តាំងពីខែធ្នូ ១៩៤៥ និង ដើមឆ្នាំ ១៩៤៦ ម្ល៉េះ ៗ

មកដល់ពេលនេះយើងមិនទាន់ឃើញមានព្រឹត្តិការណ៍អ្វីចេញជារូបរាងនៅឡើយទេ នៅស្រុកព្រែកគយ ៗ ប៉ុន្តែការហ៊ឹកហ៊ឺនទាហានយួន ដូចជារវើលជាងធម្មតា ដែល ជាហេតុមួយនាំឲ្យយើងព្រឺឆ្អឹងខ្នងខ្លាំងឡើង ១ ៗ

# អ្វីដែលត្រូវកើត ក៏កើតឡើង

ដោយគតិមានពីអគ្គិភ័យ ដែលប្រែធីនមានឡើង ដូច ជំរាបខាងលើ លោកតា ថាច់ គេង ចៅអធិការវត្តពោធិព្រឹក្ស នៅវត្តចាស់ ក៏បានចាត់លោកតា សារ អ្នកនៅបំរើព្រះសង្ឃក្នុងវត្តនេះ ឲ្យទៅសួរពត៌មានពីអ្នកជិតខាងទល់ខាងយៀក មិញម្នាក់ឈ្មោះឡុង យួនកាត់ចិន ជាអតីតមេឃុំយួនហៅ សាឡុង ផ្ទះនៅមាត់ព្រែក ពីរៀនជុតផ្សារ ដើម្បីលោក និមន្តទៅបិណ្ឌបាត កុំឲ្យធ្វើយ៉ាងនេះ ៗ លោកតា សារ មិនហ៊ានទៅផ្ទាល់ទេ តែបានទៅពឹងបងប្អូនយើងនៅផ្ទះជិត ក្បែរវត្តទៅសាកសួរឲ្យ ៗ ដោយប្រទះនឹងព្រឹត្តិការណ៍បែប នេះបងប្អូនយើង ១៦ នាក់ ដែលមានឈ្មោះ ស៊ាង ជាមេ ក៏ បានធ្វើដំណើរទៅរកយួន ឡុង ៗ គ្រាន់តែចូលដល់របងភូមិ មេឃៀកមិញបាញ់ប្រាវ ៗ តែដោយកុសលមាន បងប្អូន

យើងក្រាបទាន់ ហើយស្ទុះរត់ចូលទៅចាប់យួន ទាំងកំរោល ដណ្ដើមយកបានតែកាំភ្លើង ។ ឯមេយៀកមិញ ដាយចេញ តាមទ្វារក្រោយបាត់ទៅ ។

ក្រោយពីឧប្បត្តិហេតុទីមួយនេះកើតឡើង បងប្អូនយើង ភាគច្រើនបានបន្ទោសគ្នាថា «នៅមិននៅ នាំគ្នាបុកសំបុក ស្រាំងឱ្យផ្អើល» ។ នេះជាពាក្យមួយទៀតដែលបញ្ជាក់ឱ្យ យើងឃើញថាយើងគ្មានបំណងណាមួយប្រឆាំងដល់ចលនា របស់យួនយៀកមិញនោះទេ ហើយការពិត គឺយួនទេដែល ប្រើអាវុធសម្លាប់យើង ពីព្រោះថ្ងៃដែលក្រុមខ្មែរ១៦ នាក់ចូល ទៅរកជួបមេយៀកមិញនោះ យើងទៅដោយមានព្រះសង្ឃ ចង់ជ្រាបការពិត ដើម្បីសំណូមពរ កុំឱ្យគេ«បំផ្លាញផ្សារ» ។

ចំពោះគ្រោះកាចបែបនេះ អ្នកបន្ទោសគ្នា ក៏ចេះតែ បន្ទោសទៅ ប៉ុន្តែទាំងអស់គ្នា លែងចូលអ្វីទៀតហើយ ហើយក៏ចាប់ផ្ដើមប្រដាប់កាំបិត - ពូថៅគ្រប់គ្នាដោយចំហ ហើយចាត់គ្នាយាមគ្រប់ច្រកចូលភូមិ ទីងចាត់គ្នាឱ្យស្រង់ ពតិមានខ្លះដែលបានទទួលនូវគ្រប់ទីកន្លែង ។

វេលាថ្ងៃទី ២០ ធ្នូ ១៩៤៥ មេយៀកមិញឈ្មោះ ឡុង ដែលរត់ចោលកាំភ្លើងដូចជំរាបខាងលើ បាននាំគ្នាប្រហែល ៥០ព្វាយនាក់មកពីកោះកុងដើម នៅមាត់ទន្លេមីជាញ់ ហៅ ទន្លេឯក្សង បំណងវាយប្រហារបងប្អូនយើងនៅភូមិព្រែក

ចាក ៗ ប៉ុន្តែគ្រាន់តែមួយម៉ោងក្រោយពីចុះពីទូកសមុទ្រឡើងដល់ដីលើគោកមក ក៏ត្រូវបងប្អូនយើងប្រមូលគ្នាដេញវាយប្រហារផាប់រង្គរណែលនៅតាមវាលស្រែ ៗ យួនវៀតមិញដែលនៅសល់ពីស្លាប់ទាំងប៉ុន្មាន ក៏រត់ឡើងទូកធុងទៅរកជំរំរបស់វានៅឯកោះកុងឌីមនោះអស់វិញទៅ ៗ នៅថ្ងៃនោះយើងមានទទួលខូចខាតតែបន្តិចបន្តួច ហើយថែមទាំងយកបានអាវុធបរមាញ់មួយដើមទៀតផង ក្រៅពីគ្រាប់បែកដៃ និង ធ្នូ ស្នា មួយចំនួនធំ ៗ

បន្ទាប់ពីព្រឹត្តិការណ៍នៅភូមិព្រៃកចាកដែលនៅចម្ងាយប្រហែល ៥ គ-ម ពីភូមិព្រៃកគយមកបងប្អូនយើងបានផ្អាកកិច្ចការទាំងអស់ ហើយតែងប្រមូលផ្តុំគ្នាជាក្រុមតូច ៗ តាំតាមភូមិនានាក៏មាន នៅតាមច្រកចូលផ្សារក៏មាន តាមវត្តអារាមក៏មាន ដើម្បីប្រជុំគ្នាការពារខ្លួន ឬធ្វើអន្តរាគមន៍ ៗ

រាល់ថ្ងៃ ២៥ ធ្នូ ១៩៤៥ យួនវៀតមិញមួយក្រុមចំនួន ៧០ ហ្វាយនាក់ប្រដាប់ដោយធ្នូ ស្នា កាំបិតហាន់ដើមបេកស្ទ និងកាំភ្លើងប្រមាញ់ខ្លះ បានត្រូវបងប្អូនយើងដែលយាមនៅតាមផ្លូវចូលទៅផ្សារព្រៃកគយព័ទ្ធផាប់បំរុងដកអាវុធ ៗ ប៉ុន្តែដោយមេយៀកមិញបានឲ្យដឹងថា គោលបំណងរបស់ក្រុមគេដែលចូលមកនេះគឺដើម្បីចង់ជួបថ្វាយបង្គំលោកតា ចាច់-ពេជ ចៅអធិការវត្តពោធិព្រឹក្ស ដើម្បីសុំឲ្យលោកជួយ

ធ្វើការសំរុះសម្រួលកុំឲ្យខ្មែរ-យួន ឈ្លោះគ្នាតទៅទៀត ។ ដោយយើងឃើញថានៅក្នុងផ្លូវចិត្តយួនទាំងនោះ មានព្រះសង្ឃខាងមហាយានមួយអង្គ និមន្តជូនដំណើរមកជាមួយ ដែលយើងត្រូវតែទទួលស្គាល់ថា ជាសញ្ញាសន្តិភាពនោះ យើងក៏បានចាត់គ្នាឲ្យនិមន្តព្រះសង្ឃ ៣ អង្គនៅវត្តព្រហ្ម-វិសាល ហៅវត្ត កំពង់ឈើទាល គឺព្រះភិក្ខុ ថាច់ ចយ ព្រះភិក្ខុ លី ផា និងព្រះភិក្ខុ សុង ផា (១) ជាតំណាងព្រះសង្ឃនិងបងប្អូនយើងនៅព្រែកគយ ដើម្បីធ្វើការចរចា ជាមួយយួន ។ ក្រោយពីយើង និងព្រះសង្ឃ បានធានាអះអាងដល់ក្រុមយួនថាគោលដៅរបស់យើងគឺសេចក្តីសុខ ខ្មែរ និង យួន ត្រូវទុកគ្នាជាបង-ប្អូនដែលដូចមុននោះមក និងមុខគេដកថយទៅកុងដីមវិញ យួនបានសុំនិមន្តព្រះសង្ឃទាំង ៣ អង្គនោះនិមន្តទៅជាមួយគេ ដើម្បីជាកិច្ចធានាដល់សេចក្តីសុខរបស់គេនៅតាមផ្លូវ ។ ដោយចង់ដឹងពីគោលបំណងពិតរបស់យៀកមិញ និងចង់ដឹងពីស្ថានការណ៍នៅកុងដីមផង និងតាមសេចក្តីយល់ស្របពីលោកតា ថាច់ កេដ ព្រះសង្ឃទាំង ៣ អង្គក៏បានប្តេជ្ញាព្រះទ័យ និមន្តជូនដំណើរយួនទៅវិញ តាម

---

*(១) ឮដំណឹងថា៖ អតីតព្រះភិក្ខុ សុង ផា បានចាកសិក្ខាបទហើយ សព្វថ្ងៃធ្វើជាយុទ្ធជននៅក្នុងកងឯកភាពមួយ ក្នុងកងទ័ពជាតិ ប៉ុន្តែមិនច្បាស់ទីកន្លែង ។*

សេចក្ដីសុំរបស់គេៗសូមជំរាបថា ពេលក្រុមយួនដកថយទៅវិញភ្លាមក៏ស្រាប់តែឃើញពលរដ្ឋយួននៅផ្សារព្រែកគយរាប់ម៉ឺននាក់បានដឹកកូន ជញ្ជូនទៅ ភៀសខ្លួនចេញពីផ្សារព្រែកគយទៅតាមទ័ពយួនដែរ ដែលជាហេតុមួយនាំឱ្យយើងដឹងថា យួនដែលចូលមក ៧០ ពាន់នាក់ធ្វើជាមកចរចាជាមួយយើងនោះ ការពិតគឺគេមករំដោះជនជាតិយួនដទៃទៀតឱ្យថយចេញពីផ្សារព្រែកគយ ដើម្បីគេងាយមកវាយកម្ទេចខ្មែរយើងនៅថ្ងៃក្រោយប៉ុណ្ណោះ ។ រីឯការចរចារវាងគេនិងយើង ដូចជំរាបខាងលើ វា និងវត្តមានព្រះសង្ឃយួនគ្រាន់តែជាល្បិចសំរាប់គេដោះដៃ ឱ្យផុតពីការឡោមព័ទ្ធរបស់ក្រុមអ្នកយាមខ្មែរយើង តែប៉ុណ្ណោះ ។

ពេលទៅដល់ភូមិដីម មេក្រុមយួនបានយកព្រះសង្ឃទាំង ៣ អង្គដែលនិមន្តទៅជាមួយ ទៅគង់ក្នុងរោងដាក់ជីត្រីមួយ ឃ្លាតឆ្ងាយពីផ្ទះយួនឯទៀត លុះមួយស្របក់ក្រោយមក ក៏ស្រាប់តែមានពលរដ្ឋយួនរាប់រយនាក់ មកនិយាយដៀមដាមដាក់ព្រះសង្ឃ ធ្វើឱ្យព្រះសង្ឃកើតក្ដីរន្ធត់ជាខ្លាំងៗ បន្ទាប់មកទៀត មេទ័ពយួននៅទីនោះ បានយកកាំភ្លើងខ្លីមួយដើមមកបោះលើតុ រួចគេនិយាយទៅកាន់ព្រះសង្ឃដោយពាក្យបោះបញ្ឆោះថា: ‹‹បើអ្នកណាហ៊ានធ្វើអីលោក លោកចេះបាញ់ស្រាប់ បាញ់បំបែកក្បាលវាទៅ,, ។ ប្រ

ហែលជាម៉ោង១២យប់ថ្ងៃនោះ មេឃួនបាននាំព្រះសង្ឃទៅ មើលឃ្លាំងអាវុធដែលឃើញមានកាំភ្លើងតូច-ធំ ដាក់គំរៀប គ្នាជាច្រើនជួរ ប៉ុន្តែមេឃួនក៏បានហាមមិនឲ្យព្រះសង្ឃនិមន្ត ទៅជិតឃ្លាំងនោះទេ ដោយអាងថាក្រែងបណ្ដាលឲ្យគ្រាប់ បែកដែលស្លុតជាមួយនោះផ្ទុះ អាចបណ្ដាលឲ្យមាន គ្រោះថ្នាក់ ។ ត្រង់នេះព្រះសង្ឃអាចឃើញច្បាស់ណាស់ ថា សុទ្ធតែកាំភ្លើងឈើស៊ើងតែទាំងអស់

លុះព្រឹកឡើង មេទ័ពឃួនបានដោះលែងព្រះសង្ឃមួយ អង្គឲ្យនិមន្តយកសំបុត្រ មកប្រគេនលោកតា ថាច់ គេជ ទៅអធិការវត្តព្រៃគគយ សុំឲ្យលោកធានាអះអាងជាលាយ លក្ខអក្សរ កុំឲ្យខ្មែររករឿងនឹងឃួនទៀត ។ ក្រោយពីលោក បានបំពេញតាមបំណងរបស់វាជាលើកទីមួយហើយ ថ្ងៃ បន្ទាប់មក វាបានចាត់ព្រះសង្ឃមួយអង្គឲ្យនិមន្តយកសំបុត្រ វាមកទៀត និយាយតែរឿងដដែល ៗ លោកតា ថាច់ គេជ មិនទាន់ទាំងបានធ្វើយតបសំបុត្រទីពីរនេះផង ក៏ស្រាប់តែ ឃើញព្រះសង្ឃអង្គទី ៣ និមន្តមកដល់ទៀត ដើម្បីរឿង ដដែលទៀត ៗ មកដល់ត្រង់នេះ យើងគ្មានត្រូវការអឺធឹង ចាញ់បោកឃួនជាលើកទីពីរទៀតទេ ។ ដោយហេតុហ្នឹង ហើយបានជាយើងផ្ដាច់ការទាក់ទងត្រឹមនេះសិន ដោយ សារថាព្រះសង្ឃដែលជាប់ក្នុងកណ្ដាប់ដៃវានោះ បានរួចមក

វិញហើយ ត្រូវការអីនិងចាត់ឲ្យស៊ីវិលទៅទៀត ៗ គេ លែងព្រះសង្ឃ ពីព្រោះគេដឹងថាគេស្លូតនៅត្រង់ចំណុចខ្សោយ ៗ

✻

# អ្នកហ៊ានស្លាប់ ប្រាកដជាមិនស្លាប់

ដោយសារយួនយៀកមិញបានបញ្ចេញបំណងពិតរបស់គេឱ្យយើងឃើញច្បាស់ដូចនេះ យើងក៏បានចាត់វិធានការសព្វគ្រប់ដើម្បីទប់ទល់ ។ ដំបូងយើងបានប្រជុំគ្នារើសអ្នកដឹកនាំចលនារបស់យើង ដោយមានលោកតា ថាច់ ហ៊ុម អាចារ្យវត្តពោធិព្រឹក្ស លោកតា ឡាំ ណុប កសិករនិងបងប្អូនយើងខ្លះទៀតចូលរួមផង ។ មតិអង្គប្រជុំបានមូលមកលើថីដោយ ផាត់ ពីព្រោះជាកូនក្រោលបង្គោលស្អិតស្រាប់ ។

បន្ទាប់មកទៀត យើងបានធ្វើការបញ្ជាក់ទៅលើខ្សែបន្ទាត់របស់ចលនាយើង ពីព្រោះយើងជាជនភាគតិចនៅក្នុងកណ្ដាប់ដៃគេ ត្រូវឱ្យមានខ្សែបន្ទាត់ដែលមិនអាចនាំយើងទៅរកក្ដីវិនាសបាននៅថ្ងៃក្រោយ ។ ក្រោយពីបានជជែកគ្នាមួយលើក ជាពីរលើកមក នឹងដើម្បីឱ្យមានការគាំទ្រពីមជ្ឈដ្ឋានព្រះសង្ឃផង យើងក៏បាននិមន្តលោកតា ថាច់-

ពេជ ទៅអធិការវត្តកោធិព្រឹក្ស និមន្តចូលរួមប្រជុំដើម្បីជាទីប្រឹក្សា ។ អង្គប្រជុំដ៏សម្ងាត់នេះ បានសំរេចមាគ៌ារបស់យើងដូចតទៅនេះ ៖

១— ជៀសវាងជាដាច់ខាត កុំបង្ករឿងមុន

២— ទៀតគ្រប់ឱកាសល្អ ដើម្បីធ្វើឲ្យគេអាណិតយើង

៣— ប៉ុន្តែអ្វីដែលយើងមិនព្រមទទួល គឺកំហុសដែលគេដាក់មកលើយើង ដោយពីប៉ុន្មានថ្ងៃមុននេះ គេចោទថា យើងនាំគ្នាបះបោរប្រឆាំងនឹងយៀកមិញ ដើម្បីឲ្យបារាំងចូលមកត្រួតត្រាបានស្រួល ។ មានជួនកាលគេឲ្យគ្នាគេមកនិយាយករយើងថា គេអាណោស់ប្រសិនបើបងប្អូនខ្មែរយកដីកម្ពុជាក្រោមឲ្យខ្មែរភ្នំពេញត្រួតត្រាវិញ ពីព្រោះស្រួល « រកស៊ី »... ។

ដោយមានជំនឿទៅលើព្រះពុទ្ធសាសនាដ៏មោះមុតផង ដើម្បីលើកទឹកចិត្តអ្នកតស៊ូរបស់យើងផង យើងក៏បានបួលគម្ពីរ “ចាក់គម្ពីរ” ឃើញត្រង់សុរគត ជាអ្នកគោរពព្រះសមណគោត្តម និងករហទិន ជាអ្នកគោរពពួកព្រាហ្មណ៍នៅក្នុងលិច្ចកលដែល ករហទិនប្រើដើម្បីធ្វើគតព្រះពុទ្ធនេះបានផលផ្ទុយទៅវិញ រួមសេចក្តីមកថា ការតស៊ូរបស់យើងមុខតែមានជោគជ័យ ។

សូមជំរាបអស់លោកអ្នកអានថា តាំងពីមានរឿងទាក់ទង

ទីងព្រះសង្ឃ មកដល់ពេលយើងរៀបចំដូចជំរាបខាងលើ ភាពស្ងប់ស្ងាត់ដូចជាមានឡើងវិញដែរ ។ ស្រាប់តែរាំង ថ្ងៃ ៣០ ធ្នូ ១៩៤៥ មានយួនមួយក្រុមប្រហែល ១០០ បាយនាក់ ចូលពីកោះគុងដីមមកទៀត មកឡោមព័ទ្ធ ភូមិបង-ប្អូនយើងនៅក្នុងព្រែកបំរុងសាងវិនាសកម្ម ។ ប៉ុន្តែ បង-ប្អូនយើងបានប្រមូលគ្នាប្រយុទ្ធជាមួយខ្មាំងយួន មាន កាំភ្លើងបាញ់សត្វ៦ ដើម ក្រៅពីធ្នូ-ស្នា ខ្មែរយើងគ្មានអាវុធ អ្វីក្រៅពីកាំបិត-ដាវ-លំពែង ដូចនេះខ្មែរយើងត្រូវប្រើតាំង តែពីអំបែងពាង-ដប-ដុំអិដ្ឋ គ្រវែងទៅរកយួនតាំងពីព្រឹក ខាងអាយតាំងពីម៉ោង ១៦ រហូតដល់ម៉ោង ១៧ ។ នៅ ម៉ោងនេះ ខ្មែរយើងមួយក្រុមបានបញ្ឆោតខ្មាំង ហើយលប ចូលព្រែកទៅប្រឡូកជាមួយ ធ្វើឱ្យយួនបាក់ទ័ព ។ ថ្ងៃនោះ យើងស្លាប់ ២ នាក់ យួនស្លាប់ប្រហែល ៦ នាក់ ។

ចំពោះព្រឹត្តិហេតុថ្មីនេះ យើងលែងសង្ស័យអ្វីទៀតចំ ពោះពាក្យផ្អែមល្ហែមដូចជំរាបខាងលើនេះទៀតហើយ ។ ប៉ុន្តែយើងក៏ឥតមានផ្តើមធាក់ប្រយុទ្ធអ្វីជាថ្មីទៀតដែរ ។ ហើយយើងមានការប្រុងប្រយ័ត្នខ្ពស់ មួយជាដប់ ។

ដើម្បីជាការងាយស្រួលក្នុងការតស៊ូរបស់យើង យើង បានតាំងសេនាធិការដ្ឋានរបស់យើងនៅផ្ទះលោកតា អតីត មេសង្កាត់ ឡាំ ឈើន ស្ថិតនៅក្រោយសាលាសង្កាត់ព្រែក

គយ ។ បានជាយើងយកកន្លែងនេះ ធ្វើជាកន្លែងចាត់ការរបស់យើងដោយសារកន្លែងនេះមានស្ពានមួយ ដែលយើងត្រូវការពារ ហើយជាកន្លែងដែលព្រែកបែកជាបី ៖ មួយទៅបឹងព្រលិត-ដងក្តាន់-ដើមពោធិ-កូនក្អែក- មួយទៀតទៅផ្អាងកើត-ទៅភូមិកំបុត-ព្រែកទីបី បែកទៅរកផ្សារព្រែកគយទៅដៃនង- ចាក់ទិង- បាយឆៅ និងទីរួមខេត្តឃ្លាំង គោលគឺជាចំណុចមួយសំខាន់ខាងផ្នែកយុទ្ធសាស្ត្រ ។

បើគេឈរលើស្ពាន មើលទៅទិសខាងត្បូង គេនឹងឃើញវាលស្រែល្វឹងល្វើយដាច់កន្ទុយភ្នែកចំនួនរាប់ម៉ឺនហិកតា នៅចំហៀងខាងស្តាំដៃវាលនេះ មានព្រែកមួយ ហៅព្រែកបឹងព្រលិត ។ បង-ប្អូនយើងបានតាំងលំនៅឋាន នៅតាមមាត់ព្រែកខាងឆ្វេងដៃ រីឯពលរដ្ឋយួននៅក្រោយខាងស្តាំ ។ នៅចុងព្រែកខាងជើង មានវត្តខ្មែរមួយ ហៅថាវត្តកូនក្អែក ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីផ្សារកូនក្អែក ។ ចម្ងាយពីស្ពានវត្តកូនក្អែក ប្រហែល ១០ គ.ម ប៉ុណ្ណោះ ។ ភូមិបង ប្អូនយើងនៅទីនោះ សុទ្ធសឹងជាភូមិស្តុកស្តម្ភ មានដើមដូង-ស្លា-សន្ត្រ-អំពូរ-ស្ពៃ-ស្តាំ-ចេក-ស្វាយ ដុះពាសពេញ ជាទីសែនមនោរម្យ ។

រវាងថ្ងៃទី ២ មករា ១៩៤៦ ពេលដែលសមាជិកសេនាធិការស្រស់ស្រូបរួចផ្លូវរៀងរាល់ថ្ងៃដែរ យើងតែងទៅ

ជ្រែកលើកទឹកចិត្ត បង ប្អូនយើង ដែលយាមនៅលើស្ពាន ដើម្បីបំភ្លេចកិច្ចកន្ទល់ទាំងឡាយ ។ មួយសន្ទុះក្រោយមក វេលាម៉ោង ៧ កន្លះ ចក្ខុយើងបានទាញអារម្មណ៍យើងឱ្យផ្តោតទៅលើផ្សែង ដែលហុយផ្លោលទៅលើមេឃនៅម្តុំវត្តកូនក្អែក ហើយផ្សែងដទៃទៀត បានហុយឡើងបន្តបន្ទាប់គ្នា ដែលញាំងឱ្យយើងដឹងថា វិនាសកម្ម បានធ្លាក់មកលើបង ប្អូនយើងទៀតហើយ ។ ពេលជាមួយគ្នានោះ អ្នកនាំសារក៏បំផាយសេះមកដល់ ហើយប្រាប់ថាយួនប្រហែល ១០០ ពាយនាក់ ខ្លះជិះទូក ខ្លះដើរ បានចូលមកផុតវត្តជើងក្អែក និងផុតផ្ទះ បង ប្អូនយើងអស់ជាច្រើនខ្នង ។ អ្នកនាំសារបានបញ្ជាក់ទៀតថា ៖ ទូកយួន ដែលមានយួន ប្រដាប់អាវុធជិះក្នុងនេះ បានបើកចូលក្នុងព្រែកបឹងព្រលិត បណ្តើរ បាញ់បណ្តើរ ធ្វើឱ្យបង ប្អូនយើងភៀសចេញពីភូមិ ដើម្បីទុកឱ្យគ្នាវាដើរផុតផ្ទះតាមក្រោយ ។ និងគ្នាវាមួយចំនួនទៀត តាមជួយការពារផ្ទះយួន ដែលសង់តាមមាត់ព្រែកខាងស្តាំ ដូចជារាបខាងលើ ។

ក្រោយពីបានឮស្នូរស្គរធំជាកេរ្តិ៍សញ្ញាមក បងប្អូនយើងប្រហែល ២០០ នាក់ បានមកដល់មុនគេ ប្រដាប់ដោយ ដាវ-ស្នា-លំពែង-ធ្នូ-កាំបិតដងវែងនៅនឹងដៃស្រាប់ ។ ក្រោយពីយុទ្ធជនយើងដឹងច្បាស់នូវស្ថានការណ៍

និងវិធីរម្ងាប់ខ្មាំងមក និងដោយសារសំណូមពរដោយទទូចពីគាត់ផង យើងក៏បានប្រគល់ភារៈដឹកនាំទ័ពជូនលោកតា-ឡាំ ណុប «អាយុ ៥០ ញយឆ្នាំ» ។

គឺនៅពេលនេះហើយដែលបង - ប្អូនយើងបានឃើញទង់ជាតិរូបប្រាសាទជាលើកទីមួយ ដែលសេនាធិការយើងទើបនឹងដេរួច ហើយប្រគល់ជូនលោកតា ណុប លើកទ័ពទៅរកខ្មាំង ។

ក្រោយតែប្រហែលមួយម៉ោង ពីទ័ពយើងចេញដំណើរទៅ ភ្លើងដែលឆេះតែរំកិលជិតមកៗនោះ ក៏ឆេះថយទៅវិញ ដែលជាហេតុប្រាប់ឲ្យយើងដឹងថា ខ្មែរមានជោគជ័យហើយ ដោយគេបានដុតផ្ទះយួន ដែលរាយតាមមាត់ព្រែកខាងស្តាំនោះម្តងវិញ ។

សូមបញ្ជាក់ថា ក្រោយពីទ័ពយើងចូលទៅដល់ យើងគ្រាន់តែចែកគ្នាឲ្យទប់ទល់ខ្មាំងបន្តិចបន្តួច ដើម្បីឲ្យយួននិងយើងដាច់ដៃគ្នាសិន ហើយយើងចាត់ឲ្យគ្នាយើងមួយពួកទៀត កាប់ដើមឈើដែលដុះតាមមាត់ព្រែកស្រាប់នោះ រំលំទទឹងព្រែកដើម្បីយាំងទូកយួន កុំឲ្យវាធ្វើចលនាទៀតកើត និងបង្ខំយួនដែលនៅក្នុងទូកនោះឲ្យឡើងគោកផង ដើម្បីកំទេចវាជាក្រោយ ។ ហេតុដូចនេះហើយបានជានៅពេលដែលទឹកនាច ផ្ទៃទឹកស្រកចុះច្រើន ខ្មាំងនៅក្នុងទូកដែល

ត្រូវមាត់ច្រាំងព្រែកចាំងក្អែក មើលមកយើងមិនឃើញ បាន
នំកាសល្អញាំងយើងឱ្យលួនទៅជិតទូកបាន ហើយគប់ទូក
នោះចឹងដុំឈើ-ដុំដី-គ្រាប់បែកស៊ីម៉ង់ត៍ ។ យួនទ្រាំមិនបាន
ក៏រត់ចោលទូក គឺនៅពេលនោះហើយដែលធាកប្រយុទ្ធដ៏
សាហាវវាងខ្មែរ និង យួនបានកើតឡើង ។ នៅពេលវាបាក់
ទឹក យុទ្ធជនយើងបានដេញកាប់សត្រូវទាំងស្រស់ ដេញ
ប្រហែល ២គម. យួនអស់គ្រាប់ ខ្មែរដេញយួនរហូតផ្សារ
កូនក្អែក ចម្ងាយពីកន្លែងប្រយុទ្ធដំបូងប្រហែល ៤គម. ។
ត្រង់នេះយើងសូមបើកវង់ក្រចក ដើម្បីសំដែងសេចក្តីសោក
ស្តាយ ដោយយុទ្ធជនដ៏ក្លេវក្លាម្នាក់ឈ្មោះ ថាច់ វង់ ត្រូវជា
ក្មួយលោកតា ថាច់ ពេជ ដែលត្រូវរបួសនៅក្រោយផ្សារ
កូនក្អែក ហើយត្រូវយួនអារកបាន ដោយគ្នាយើងរត់ទៅ
ជួយមិនទាន់ ។

នៅពេលដែលទឹកយើងត្រឡប់មកវិញ ដំណឹងពីយួន
ដុតវត្តកូនក្អែក បានហិចហើរលាន់ឮរន្ទឺទៅគ្រប់ទិសទី ដូច
ស្គរផ្គរលាន់ ។ នេះជាកំហុសមួយធំ ក្រៃណាស់ ដែលយួន
បានប្រព្រឹត្តមកលើខ្មែរ មកលើសាសនាដែលខ្មែរទូទៅ
គោរព ។ ផ្ទះខ្មែរនេះ ខ្មែរឥតគិតទេ ប៉ុន្តែអ្វីដែលខ្មែរ
គោរព ហើយត្រូវគេធ្វើឲ្យអប្បរស្មី ខ្មែរឈឺចាប់រកទីបំផុត
គ្មាន ។

ដោយសារវត្តកូនក្លែកគ្រាប់បំផ្លាញ ខ្មែរ និង យួន បើកឆាក ប្រយុទ្ធកាប់សម្លាប់គ្នាសឹងគ្រប់ទិសទី សាយភាយរហូតទៅ ដល់ទីប្រជុំជន បាយនៅ-ចាក់ទ្រង់ ។ល។ ដែលនៅឆ្ងាយពី ព្រៃគគយប្រហែល ៦០ គ.ម ។ នៅស្រុកខ្វះនៃខេត្តពល លាវ ក៏ដូចនេះដែរ ។ ខ្មែរ និងយួន បានចោទគ្នាទៅវិញ ទៅមកតែអ្វីដែលយួនមិនព្រមរក គឺឫសគល់ គឺប្រភព គឺ មេភ្លើងដែលញុាំងខ្មែរ និងយួនឲ្យនិយាយស្តាប់គ្នាលែងបាន ដូចបុរាណលោកប្រៀបទៅដើមចេក និងក្របីដូវឆ្លោះឯង ។

ហេតុដូចនេះហើយទើបរៀងរាល់ថ្ងៃ គេតែងឃើញ អគ្គិភ័យគ្រប់ទិសទី ។ ឯនេះ ខ្មែរដុតផ្ទះយួន ។ ឯនោះយួន បំផ្លាញគេហដ្ឋានខ្មែរ ។ នៅតាមព្រែក ពីព្រៃគគយ ទៅ បាយនៅ បណ្តោយប្រហែល ៦០ គ-ម ប៉ុណ្ណោះ គេ ឃើញមានសាកសពខ្មែរ និងយួន អណ្តែតរដូករណែលរាប់ រយ ។ នៅតាមព្រែកដទៃទៀត ក៏មិនខុសគ្នាប៉ុន្មានពីព្រែក នេះដែរ ។ អ្នកស្រុកមិនហ៊ានទទួលទានទឹក តមមិនយក អន្ទង់-បង្កង-បង្គា-ត្រី-ក្តាមសមុទ្រ ។ល។ ធ្វើអាហារទេ ។

ក្រុមយើងតែងលើកគ្នាទៅជួយនៅកន្លែងណាដែលត្រូវ ការ ។

សូមជំរាបថា មកដល់ពេលនេះ យើងមានតែកាំបិត- ពូថៅ ដើម្បីការពារខ្លួន ។ ប៉ុន្តែអ្វីដែលជាកម្លាំងកំពូល

របស់យើង គឺជំនឿលើខ្លួនឯង លើការរួបរួមគ្នា លើការចេះស្តាប់គ្នា ចេះគោរពបទបញ្ជា មានវិន័យថ្លៃថ្នូរ ។ ឧទាហរណ៍ ពេលប្រុស ៗ ទៅប្រចាំការនៅសេនាធិការដ្ឋានដែលមានចំនួនរាប់ពាន់នាក់រៀងរាល់ថ្ងៃ ស្រី ៗ ណាដែលពៃទៅបាន ៗ ទៅជួយរៀបចំបាយទឹក ជូនយុទ្ធជនគ្រប់ពេលវេលា ។ ពិតមែនតែយើងគ្មានប្រាក់សំរាប់ចំណាយ ប៉ុន្តែបាយ ម្ហូប មិនចេះខ្វះ ពីព្រោះម្នាក់ ៗ ដែលអញ្ជើញមករួបរួមកម្លាំងគ្នាទោះក្នុងឋានៈជាយុទ្ធជនក្តី ជាអ្នកមានមុខការផ្សេង ពីនេះទៀតក្តី មិនដែលអញ្ជើញមកដៃទទេទេ អ្នកក្រីក្រក៏សុខចិត្តចូលរួមក្នុងការប្រយុទ្ធដូចគ្នា ជាពិសេសពូ ៗ ដែលមានវ័យចាស់ទៅហើយ ក៏បានមកជួយរែកទឹក ពុះឧសបិតចង្កើះ លើកដាក់របស់របរផ្សេង ៗ ។ ក្រៅពីជំនឿលើខ្លួនឯង យើងមានជំនឿទៅលើព្រះពុទ្ធសាសនាមុតមាំណាស់ ។ ហេតុដូចនេះហើយបានជានៅពេលមុនចេញទៅបំពេញសកម្មភាពម្តង ៗ អ្នកដែលចេះធម៌ព្រះពុទ្ធតែងសូត្រប្រក់ព្រំផ្លុំងដល់យុទ្ធជនយើង ‹‹អស់ទឹកទាំងពាង,, ធម៌ដែលយកមកប្រើ គឺធម៌ឥតិបិសោ . . . . . ។

កាំភ្លើងដែលយើងយកបានពីខ្មាំងបីដើម មានមួយដើមបាក់ពេលប្រយុទ្ធគ្នា ពីរដើមទៀតជាកាំភ្លើងប្រមាញ់ យើងទុកសម្រាប់តែបាញ់ពេលដោះកុនម្តង ៗ ឬ បាញ់សំឡុត

សត្រូវព្រោះមិនសូវមានគ្រាប់ ៗ ហើយកាលនោះ នៅពេលប្រយុទ្ធគ្នាម្តង ៗ យួនក៏ពុំសូវមានអាវុធអ្វីក្រៅពីមុស្គើតុង កាំភ្លើងប្រមាញ់ និងព្រួញ-ស្នា កាំបិតស្នៀត ដែលយួនហៅថា កាំបិត "យួគិច" ខុសគ្នាពីខ្មែរយើងដែលប្រើតែព្រនង់មានកាំបិតខាងចុងម្ខាងដាវ - លំពែង - កាំបិតវែង-ស្ន-ឲ្យក និងកាំបិតយួគិចដែរ គ្រាប់បែកដៃធ្វើពីស៊ុមីង់ត៍មានបន្ទាដែកគោល យើងធ្វើបានខ្លះខុកប្រើការពេលប្រឡូកគ្នាៗ កាំភ្លើងអាយ ដែលគេធ្វើដោយអារតួកង់នោះ យើងធ្វើសម្រាប់តែយកស្នូរ ឲ្យឮតែប៉ុណ្ណោះ «ដូចយៀកកុងវាយចោតដែរ» ៗ

ការមានប្រៀបលើសត្រូវ ដែលនាំឲ្យយើងរួចពីស្លាប់រហូតមកដល់ពេលនេះ គឺស្ថិតនៅលើវីរៈភាពដែលបងប្អូនយើងមាន ៗ អ្នកដឹកនាំចិត្ត ទោះចាស់ក្តី ក្មេងក្តី ច្រើនតែជាអ្នករហ័សរហួន រីឯយុទ្ធជនទៀតសោត មានការឆ្លាតវាងវៃហួសពីការស្មាន ៗ

ដូចនេះអ្វីដែលយើងនៅខ្វះ គឺខ្វះសេចក្តីសង្ឃឹមទៅលើអានាគតរបស់យើង បើយើងហើយនៅចាំតែរងដូចនេះតទៅទៀតមិនបង្ហាញឲ្យសត្រូវរបស់យើងឃើញ ស ឃើញខ្មៅម្តងទេ ៗ

ហេតុនេះហើយ បានជា ក្រោយពីមានការប្រជុំពិគ្រោះយោបល់គ្នាដោយសម្ងាត់មក យើងបានសម្រេចថា ត្រូវតែស្វែងរកទិញអាវុធ ឲ្យបានយ៉ាងតិច ១០ ដើមបាញ់ ដើម្បីសម្រេចគោលដៅរបស់យើង ឲ្យទាន់ពេលវេលា ពីព្រោះស្រែដែលទុំក្រហមសឹងពេញវាល យើងច្រូតមិនទាន់បានពាក់កណ្ដាលនៅឡើយនេះម៉្យាង ម៉្យាងទៀតយើងត្រូវគិតដល់រដូវស្រែខាងមុខ និងការរៀបចំសង់លំនៅដ្ឋាន និងភូមិដែលត្រូវឆេះ ឬត្រូវបំផ្លាញឡើងវិញឲ្យបានមុនរដូវវស្សាជាចាំបាច់ ។

ដោយភារៈកិច្ចរកកាំភ្លើងនេះ ត្រូវធ្លាក់មកលើថីដោយផាត់ យើងក៏បានចេញដំណើរ វេលាថ្ងៃ ១២ មករា១៩៤៦ ឆ្ពោះទៅទីរួមខេត្តឃ្លាំង ជាមួយយុទ្ធជន ៦ នាក់ ក្នុងចំណោមនោះ មានលោក ឡាំ ព្រែត ជាអតីតពលបាលទោ ហៅថីដោយ ព្រែត ទៅជាមួយដែរ ។

តាមផ្លូវពីព្រៃកគយ ទៅដល់ភូមិចាក់ទ្វិង ចម្ងាយប្រហែល ១៥ គ.ម ពុំមានអ្វីនាំឲ្យបារម្ភទេ ប៉ុន្តែចាប់តាំងពីចាក់ទ្វិងទៅ ជាតំបន់មានសុទ្ធតែពលរដ្ឋយួននៅ ដូចជាទីប្រជុំជនបាយនៅ និងភូមិជាច្រើនពីបាយនៅ ទៅទីរួមខេត្តឃ្លាំងជាដើម ។ ដូចនេះយើងត្រូវផ្សងព្រេងដោយកាត់តាមវាលស្រែ សសៀរតាមជាយភូមិយួនតូច ៗ ដែល

មានចាប់ពីត្រើយព្រែកម្នាស់ឆ្ពោះទៅរកភូមិខ្មែរ យួនមួយក្បែរ ទីរួមខេត្តហៅថាភូមិ ខយ៉ូរ «ប្រែមកថាភូមិឃ្លាំងប្រេង» ចម្ងាយពីភូមិចាក់ខ្មិងទៅប្រហែលជា ៧ គ.ម ។ ដើម្បី ជៀសវាងគ្រោះថ្នាក់ដែលមានឡើង ក្នុងពេលឆ្លងកាត់ភូមិ សត្រូវ យើងត្រូវពួនសំរាកដោយជ្រកតាមព្រៃកំប៉ុត ។ ពេលដែលយើងចូលទៅដល់កន្លែងលាក់ខ្លួន ក្បែរមាត់ព្រែក សាកសពដែលអណ្តែតសន្សឹម ៗ តាមដំណោរទឹកក្បែរយើង បាននាំឲ្យយើងកើតក្តីសង្វេគនឹកគិតដល់បងប្អូនយើងឯព្រែក គយ នឹកដល់គ្រួសារយើង ដែលទើបទទួលការឈឺចាប់ ព្រោះមានកូនប្រុសមួយស្លាប់ ដោយការនៀយហត់ និងតក់ស្លុត នៅពេលម្តាយនាំរត់កាត់វាលចម្ងាយ ៧ គ.ម និងនឹក ដល់គ្រោះភ័យដែលរង់ចាំយើងថ្ងៃស្អែក ។ ពេលដែល យើងត្រូវឆ្លងកាត់ភូមិយួន តើយើងត្រូវអណ្តែតទឹក ដូចគ្នា នេះដែរឬ ? ប៉ុន្តែក្តីកង្វល់ទាំងនេះ វានៅតែត្រឹមក្តីកង្វល់ វាគ្រាន់តែធ្វើឲ្យយើងដេកមិនលក់ ពីព្រោះវាសនាបង ប្អូន យើងរាប់ម៉ឺននាក់បានដាស់សតិយើង មិនឲ្យមានក្តីរារែកអ្វី ទៀតជាដាច់ខាត ។

នៅម៉ោង ៤ ទៀបភ្លឺ យើងរៀបចំចេញដំណើរ បំបែក គ្នាយើងជាក្រុមតូច ៗ ៣ ក្រុម ហើយយើងសន្យាទៅជួប គ្នានៅ ខយ៉ូរ ចាប់ពីម៉ោង ១០ ព្រឹកទៅទល់គ្នានឹងយប់ ។

ប្រហែលម៉ោង ៥ ស្រាងៗក្រោយពីចូលព្រៃក្រូច ហើយយើង បំបែកគ្នាជ្រែងព្រៃតែរៀងខ្លួន ៗ រហូតម៉ោង ៥ នៅ កម្ពុជាក្រោមហៅ ក្រហមឯកើត «ព្រះអាទិត្យចាប់រះ» ស្នូរកាំភ្លើងបានឮឡើងប្រហែលជាមួយគីឡូម៉ែត្រពីយើងក្រោយបន្តិចមក ឮស្នូរខ្ទរព្រលទ្រហឹងអឺងកងនៅកន្លែងដែលយើងឥតមានអ្វីខ្វល់ទៀតទេ បង ប្អូនរួមអាវុធក្រុមណាមួយត្រូវខ្មាំងប្រហារហើយ ៗ លុះយើងទៅដល់ ទឃ្លើរ ការស្មានរបស់យើងក៏ទៅជាការពិត ប្អូនឈួន និង ប្អូនពី ត្រូវយួនចាប់សម្លាប់ស្រេច ៗ

ពេលចូលទៅដល់ទីក្រុងនៅពេលយប់ មិត្តភក្តិយើងឈ្មោះ នៅ សាញ់ ដែលធ្លាប់បំរើកងទ័ពជួចគ្នាកាលជំនាន់នោះ បានជួយទាក់ទងជាមួយនាយទាហានជប៉ុនដែលរង់ចាំទ័ពសម្ពន្ធមិត្តមកដកអាវុធ ហើយទិញអាវុធ ១៦ ដើមតម្លៃតែពីរម៉ឺនពីរ្យាស( Piastres )ចាំយប៉ុណ្ណោះ ៗ

ចាប់តាំងពីយើងមានពីសភ្ញាម យើងរីករាយណាស់ ៗ រីករាយទៅទៀតត្រង់មិត្តភក្តិយើង គេជួយរើសអ្នកស្ម័គ្រចិត្តដែលគេទុកចិត្តទៅជួយយើងបាន ៨ នាក់ទៀត គ្រប់តាមចំនួនអាវុធ ១៦ ដើម ៗ យើងសូមបើកនៅក្រចកបញ្ជាក់ថា អាវុធដែលទិញបាន យើងឥតហ៊ានបញ្ចេញឱ្យអ្នកផងឃើញទេ ពីព្រោះវាអាចទៅជានាំឱ្យគ្រោះថ្នាក់ដល់យើងផង

ដល់នាយទាហានជប៉ុនដែលអាណិតយើងនោះផង ។ នៅ
តាមផ្លូវវិលទៅព្រែក ឆយ ទៀតសោត យើងចេញដំណើរ
នៅពេលក្មេងដេកលក់ យើងស្ទូតដំណើរតែមួយយប់ដល់
ភូមិ ដៃនង ចម្ងាយប្រហែល ៦០ គ.ម ពីឃ្យាំងដោយដើរ
កាត់តាមវាលស្រែឆ្ងាយពីភូមិអ្នកស្រុក ។

ពេលចូលដល់ភូមិ ដៃនង ដែលជាភូមិខ្មែរមួយស្ដុក
ស្ដម្ភ នឹងក្រោយពីបានលាក់អាវុធក្នុងព្រៃចាកមក យើង
បង្ហាញខ្លួនឱ្យអ្នកស្រុកឃើញ ដើម្បីសាកសួរពីស្ថានការណ៍
ខាងមាត់សមុទ្រ ។ យើងស្នាក់នៅក្នុងភូមិនេះចំនួនមួយ
សប្ដាហ៍ ឥតឱ្យមានលេចឮពីរឿងយើងមានអាវុធទេ ។
បានជាយើងត្រូវប្រើកលល្បិចដូចនេះ ពីព្រោះយើងចង់ឱ្យ
សត្រូវដែលតែងតែមកក្ដោបដុតផ្ទះ កាប់សម្លាប់ បង ប្អូន
យើងនោះ ចូល សិងយើងម្ដងវិញ ។

• នៅថ្ងៃ ១៨ មករា ១៩៤៦ អ្នកនាំសារមកពីសេនា
ធិការរបស់យើង បានមកឱ្យយើងដឹងថា មេទ័ពស្ទួននៅ
កោះកុងជីម បានឱ្យយើងដឹងថា យើងត្រូវឈប់ឈ្លោះគ្នា
ហើយដើម្បីបង្ហាញការស្មោះត្រង់របស់យើង យើងត្រូវប្រ
គល់ទង់ជាតិរូបប្រាសាទទៅឱ្យគេ បើពុំនោះទេ គេនឹងទៅ
ហៅទ័ពបន្ថែមពីខេត្តព្រះត្រពាំង មកកំទេចយើងឱ្យអស់ ។

ចំពោះការគំរាមកំហែងបោកប្រាសយ៉ាងនេះ យើងក៏

បានតបទៅគេវិញថា ទង់ជាតិរបស់យើងជ្រុះបាត់នៅពេលប្រយុទ្ធគ្នា នៅបឹងព្រលិតនោះទៅហើយ ។ អង្វរគេឲ្យគេអាណិត ។

ដោយជួបប្រទះនិងស្ថានការណ៍ថ្មីបែបនេះ យើងត្រូវមានការប្រុងប្រយ័ត្នលើសដើម ដោយហេតុនេះបានជាយើងចាកចេញពីដែនដីដោយទូក ធ្វើដំណើរទៅតំបន់មាត់សមុទ្រដែលជាកន្លែងយួនធ្លាប់ចូលមកធ្វើបាបយើង ។

នៅតាមផ្លូវ លុះចូលទៅដល់ផ្ទះលោកតា ថាច់ ហ៊ុម នៅក្បែរសេនាធិការដ្ឋានយើង ក៏ស្រាប់តែមានអ្នកនាំសារបំផាយសេះមកឲ្យដំណឹងយើងថា អ្នកយាមនៅតាមមាត់សមុទ្រកូនក្អែក ឃើញពលនាវាទូកក្តោងជាច្រើននៅពេលព្រលប់ នៅចុងកោះពាក់កន្ទុល ក្រោយដៃសមុទ្រម្ខាងនៃផ្សារកូនក្អែក«ជាកោះដែលល្បប់ទន្លេមេគង្គបង្កបង្កើតឡើង» ។ ប្រហែលពីរម៉ោងក្រោយមក គឺវេលាម៉ោង ៦ ព្រឹក អ្នកនាំសារម្នាក់ទៀត បានមកដល់ប្រាប់យើងថា ទ័ពយួនចំនួន ៦៧ ទូកសមុទ្រ បានចូលមកតាមទ្វារទំនប់ព្រែក កូនក្អែក ហើយចាប់បាញ់អ្នកស្រុក និង ដុតបំផ្លាញផ្ទះជាច្រើនខ្នង ។ អ្នកនាំសារបានបញ្ជាក់ទៀតថា បង ប្អូនយើងដែលរត់មកពីភូមិខ្ទិនតាងមកជួយ ចូលមិនចុះ ដោយយួនបាញ់ខ្លាំងពេកប៉ុន្តែបង ប្អូនទាំងនោះមិនព្រមត្រឡប់ទៅវិញទេ រង់ចាំ

យើងលើកគ្នាទៅជួយ ៗ បង ប្អូន យើងខាង កូនក្អែក អ្នករងគ្រោះ ដែលបានជន្លៀស ស្រី-ចាស់-ក្មេង ទៅភូមិ ដើមពោធិ៍និងទៅភូមិ ព្រែកគយ ក៏បានប្រដាប់កាំបិត ពូថៅ ចាំយើងដែរ ត្រង់នេះសូមបញ្ជាក់ថា បងប្អូនយើងឥតមាន ដំណឹងថាយើងមានអាវុធ ១៦ ដើមនេះនៅឡើយទេ ៗ

ក្រោយពីយើងយកអាវុធពីទូកមកបង្ហាញគាត់លោកតា ថាច់ ហ៊ឹម អាយុជិត ៦០ ឆ្នាំទៅហើយ តែដោយអំណាច សេចក្តីត្រេកអររបស់គាត់ ៗ ស្ម័គ្រចិត្តទៅច្បាំងជាមួយ យើង ៗ សូមជំរាបថា លោក ថាច់ ហ៊ឹម ជាអាចារ្យវត្ត ពោធិព្រឹក្សផង ជាគ្រូភ្លេងពិណពាទ្យផង ជាគ្រូប្រក់ព្រំទ័ព យើងផង និងជាទីប្រឹក្សារបស់សេនាធិការយើងផង ៗ

ដើម្បីធ្វើឲ្យខ្មាំងបណ្តោយឲ្យយើងចូលកិត យើងក៏ សម្រេចចិត្តរុំកាំភ្លើងនឹងកន្ទេលខ្លះ ខ្លះទៀតចងផ្កាបច្ចស្ស៊ី ធម្មតា ៗ សូម្បីបង ប្អូនយើងក៏ប្រឡំដែរ ៗ យើងទៅ ដល់ទីលានប្រយុទ្ធវេលាម៉ោង ៨ ព្រឹក ៗ នៅតាមផ្លូវបង ប្អូនយើង ដែលរង់ចាំយើង រាប់ច្រើនរយនាក់បាន «ហែ» យើងទៅ គេហែដោយសារគេទុកចិត្តទៅលើកាំភ្លើងប្រ មាញ់ ពីរដើមដែលគេធ្លាប់ឃើញគ្រប់សមរភូមិមកហើយ ៗ បង ប្អូនយើងខ្លះដែលស្តាយទ្រព្យរបស់ពេក ក៏ស៊ូនៅរត់ គេចចុះគេចឡើង តាមផ្លូវដើមផ្លូវក្នុងភូមិ ដើម្បីបណ្តោះសត្

ពាហនះនិងរបស់ដែលនៅសល់ខ្លះ ៗ ពេលនោះយួនឥតរវល់នឹងយើងទេ គេគិតតែពីសាងវិនាសកម្ម ៗ

នៅប្រហែល ៣០០ ម ពីភូមិ យើងចាប់ស្រាយមួរកន្ទុល ស្រាយបំពង់ឫស្សី អ្នកស្រុកដែលដើរពីក្រោយគ្រាន់តែឃើញការភ្លើង ១៦ ដើមថ្មីស្រឡាងភ្លាម ស្រែកហ៊ោសឹងរបើកមេឃ លុះដើរបានប្រហែល ១០០ ម ទៅមុខទៀត ក៏ចំពួកយួនរត់សំរុកមករកយើង ស្រែកបណ្ដើររត់ចូលបណ្ដើរ ជាមួយការភ្លើងពីរដើម ដែលយើងឃើញច្បាស់ ការភ្លើងឯទៀត ប្រហែលជាជាប់នៅការពារពួកដុតផ្ទះ ៗ គ្រាន់តែឮស្នូរវា យើងដឹងស្រេចថា ជាការភ្លើងប្រមាញ់ ៗ

លោកតា ហ៊ឹម ដែលគាត់ទើបតែស្គាល់ការភ្លើងជាលើកដំបូង ហើយទើបរៀនបាញ់ពេលមុនចេញពីផ្ទះសោះនោះ បានធ្វើឲ្យលោះកៃទៅត្រូវមេឃអស់មួយគ្រាប់ ៗ យួនឮផ្ទុះនេះ រឹតតែស្រែកៈ ទៀង- ទៀង- ទៀងតឹយ. « ចូល- ចូល- ចូលឲ្យកើត » ខ្លាំងឡើង ៗ ដោយស្រែកប្រាប់គ្នាថាៈ « ស៊ុងយ៉ា » « ការភ្លើងធ្វើអាយ » លុះឃើញមួយគ្រាប់ទៀតល្បើកភ្លឺស្រែ ចំពួកយួនយៀកមិញក៏ទប់ដំណើរភ្លាម ប៉ុន្តែមួយប៉ព្រិចភ្នែកក្រោយមក ក៏របាលចូលមករកចំពួកយើងទាំងគំរោល ៗ ការប្រឡូកគ្នា ក៏បាន

ចាប់ផ្ដើមឡើងប្រៀបបានដូចរន្ទះទាំង ៧ ។

ប្រហែលជាកន្លះម៉ោងក្រោយមក ទ័ពខ្មែរដែលពោរពេញទៅដោយកំហឹងស្រាប់ ក៏បានវាយសន្ធាប់ទ័ពយួនឲ្យដោះដៃពីវាលស្រែ ថយចូលទៅរកភូមិដែលវាទើបបានដុតបំផ្លាញនោះវិញ ។ លុះប្រកាប់ប្រចាក់គ្នានៅជុំវិញអគ្គិភ័យនោះប្រហែល ១០ នាទីមក ទ័ពយួនក៏ត្រូវបង្ខំចិត្តលោតចុះក្នុងព្រែកកូនក្អែក ក្នុងគោលបំណងឆ្លងទៅត្រើយម្ខាងទៀត ប៉ុន្តែក្នុងចំណោមមនុស្សប្រហែល ២០០ ញាយនាក់ ដែលបានលោតចុះក្នុងព្រែកនោះ មានមួយភាគត្រូវធ្លាក់ក្នុងអន្ទាក់របស់បង ប្អូន យើងដែលមកពីទិសខាង ។ ម្យ៉ាងទៀតទូកសមុទ្រចំនួន ២៧ គ្រឿង ដែលយួនយៀកមិញធ្វើដំណើរឆ្លងសមុទ្រ មកដុតបំផ្លាញផ្ទះ និងកាប់សម្លាប់ បងប្អូនខ្មែរយើង ដែលចងលាក់ក្នុងព្រែកក្បែរសមុទ្រ ក៏ត្រូវបង ប្អូនយើង មួយក្រុមទៀតមកពីបឹងព្រលិត បំផ្លាញខ្ទេចខ្ទីអស់ដែរ ។ យួនឯទៀត ដែលបាក់ទ័ពរត់ប្រសេចប្រសាចពីលានប្រយុទ្ធ បានរស់រានមានជីវិតខ្លះ ក៏ដោយសារតែរត់ទៅពួនក្នុងព្រៃចាក នៅក្បែរមាត់សមុទ្រ ឬនៅតាមភូមិយួនដែលស្ថិតនៅឆ្ងាយពីសមរភូមិ ។

ក្រោយពីបានទទួលជោគជ័យ និងប្រមូលបានអាវុធ ១០ ដើមញាយ និង ព្រួញ- ស្នា- លំពែង- កាំបិតយួគិច

ប្រហែលចំណុះ មួយខួកមក និងក្រោយពីបានប្រគល់អ្នករបួសឱ្យក្រុមចិននៅក្នុងក្អែកជួយព្យាបាល និងសំដែងសមានទុក្ខចំពោះគ្រួសារអ្នកស្លាប់ ២០ ចុយនាក់នោះមកយើងក៏បាននាំឱ្យក្រុមកាកបាទក្រហម ដែលកើតឡើងក្នុងជំនាន់យៀកមិញ ជួយប្រមូលសាកសពយួន យកទៅកប់ឱ្យបានត្រឹមត្រូវផង ។

មិនតែប៉ុណ្ណោះ យើងបានចែកគ្នាឱ្យចេញទៅ ល្បាតតាមមាត់សមុទ្រចំនួនច្រើនថ្ងៃ និងបានចាត់គ្នាយើងពីរក្រុមទៀត ឱ្យដើរល្បាតគ្រប់ទិសទី ដើម្បីទប់ទល់នឹងប្រតិកម្មផ្សេង ៗ ដែលអាចកើតមានឡើងពីខ្មាំងទៀត ។

* *

*

បន្ទាប់ពីការទប់ទល់ប្រកបដោយជោគជ័យនេះចំនួនប្រហែល ១៥ ថ្ងៃមក ក៏គ្មានឃើញហេតុភេទអ្វីជាដុំកំភួនកើតឡើងទៀតទេ រីឯការកាប់សម្លាប់គ្នានៅតាមភូមិនានា ក៏មានការថមថយច្រើន ។

ប៉ុន្តែវិនាសកម្ម បានធ្ងន់ទៅបន្តបង្កើតនៅក្នុងខេត្តពលលាវឯណោះ ហេតុដូចនេះហើយ បានជាយើងត្រូវរំលែក

គ្នាទៅជួយ បង ប្អូនភូមិស្វាយ ហើយជំរុលទៅចាប់ដៃនឹង លោកគូ គិន ហៅទៅហ្វាយ គិន ដែលជាអ្នកដឹកនាំពល នាគស្វិរបស់បង ប្អូនយើងនៅជ្រោយញរ ទេក្គពលលារ ៗ ពេលត្រឡប់វិលវិញ យើងបានវាយរំដោះ បានអ្នកជាប់ឃុំ ចំនួន ៣៧ នាក់ ដែលសត្រូវចុកយកទៅឲ្យ «រារបក្កជ» នៅពេលចូលទ្វាំបិន-យូនរូច ៗ រារបក្កជ ជាកាសិតយួន បន្ទុលការសម្លាប់មនុស្សដោយជ្រមុជទឹក ឬ កាប់បណ្តែតទឹក ។ ៗ

# ពន្លឺសន្តិភាព

ក្រោយការប្រយុទ្ធនៅ ភូនក្អែក និងក្រោយពីយើងត្រឡប់មកពីជួយបង ប្អូនយើងនៅខេត្តពលលាវចំនួនប្រហែលមួយខែមក ទ័ពសម្ពន្ធមិត្ត មិនទាន់ហ៊ានចូលមកធ្វើការរៀបរយវិញទេ ប៉ុន្តែជាមួយគ្នានេះ ការស្ងប់ស្ងាត់ក៏កើតមានឡើងសឹងគ្រប់ទិសទី ក្នុងតំបន់មួយ ដែលមានផ្ទៃដីទំហំប្រហែល៦០០ គ.ម.២. សាកសព ដែលធ្លាប់ឃើញអណ្តែតតាមព្រែកនានា រាប់រយរាប់ពាន់ ខ្លះរលេះ រលួយអស់ទៅហើយ ខ្លះក៏អណ្តែតកាត់ទីប្រជុំជន បាយនៅ ចេញទៅសមុទ្រអស់ទៅដែរៗ

រវាងយប់ថ្ងៃទី ៦ កុម្ភៈ ១៩៤៦ គេឃើញលោកតាចៅអធិការ ចាប់ ពេជ លោកតាអាចារ្យ ចាប់ ហ៊ឹម លោកតាសារ ជាអ្នកបំរើព្រះសង្ឃក្នុងវត្តគោធិព្រឹក្ស មេចិនឈ្មោះ ហួរ ហៅថៅកែ ហួរ អតីតមន្ត្រីយួនឈ្មោះ វិញ យ៉ុវ៉ង ហ ហៅ ធា ហ អ៊ុងកាឡា និង ត្រឹង យ៉ាង យ៉ំ ម្ចាស់ហាងលក់មាស «មានគ្រួសារជាខ្មែរ» ចាងហ្វាងសា

លាចិនដែលយើងកោតឈ្មោះ ហ៊ា ម៉េង ហ៊ា ប៊ុ ហ៊ា គួយ ជាអ្នកមានធនធានស្តុកស្តម្ភ បាននិមន្ត និងអញ្ជើញ មកជួបយើងក្នុងសេនាធិការដ្ឋាន ក្នុងឋានៈជាអ្នកនាំពាក្យ របស់ពលរដ្ឋយួន និងចិន នៅផ្សារព្រែកគយ ដោយស្នើសុំយើងដូចតទៅ :

–សូមឱ្យលើកសេនាធិការដ្ឋានទៅឯទីប្រជុំជន ដោយគេជូនផ្ទះមួយល្វែង ។

–សូមជួយណែនាំខ្មែរ និងយួន ឱ្យនិយាយស្តាប់គ្នាបាន លែងប្រកាប់ប្រចាក់គ្នាតទៅទៀត ។

ចំពោះការស្នើរបស់អ្នកនាំពាក្យនេះ យើងបានជំរាបបញ្ជាក់ថា: ដែលយើងទ្រាំទ្រលំបាកវាលស្រែ ខោលស្រវាសពេញវាលដូចនេះ ក៏ដើម្បីសេចក្តីសុខ និងយុត្តិធម៌ ប្រសិនគេមានបំណងដូចយើងដែរ យើងគ្មានការអ្វីនឹងបញ្ជាក់ទៀតទេ ។

មួយថ្ងៃក្រោយមកទៀត ក្រោយពីបានចាត់ការឱ្យប្រុងប្រយ័ត្នគ្រប់ច្រកល្ហកខ្វះឡើងទៀត យើងក៏បានទៅថ្វាយបង្គំលោកតា ពេជ ដើម្បីស្នើយោបល់ក្នុងរឿងនេះ ពីព្រោះយើងពិបាកនឹងទុកចិត្តគេដែរ តាមឧបត្តិហេតុ ដែលយើងបានឃើញជាហូរហែរហូតមកថ្ងៃនេះ ។ ចំពោះយើងវិញ យើងឥតមានសង្ស័យបន្តិចបន្តួចសោះទេថា: នាក

ប្រយុទ្ធនៅ ភូនក្លែក ដែលទើបកន្លងទៅនេះ បានធ្វើឱ្យយួនមានការត្រិះរិះមិនតិចឡើយ ជាពិសេស គេទើបជឿ ហើយឃើញថា យើងប្រាកដជាមិនព្រមស្លាប់មែន ។

ដោយត្រូវគោរពនូវពាក្យបុរាណដែលចែងថា បើដេញទាន់ កុំជាន់កែងនោះ យើងក៏បានធ្វើបទបញ្ជាឱ្យយួនបាត់ គ្នាគេទៅហៅមនុស្ស «រាប់ទាំងពួកកងឆ្នក់ ឬ យួកិច» ផង រាប់ច្រើនម៉ឺននាក់ ទៅនៅតាមកោះនានា នៅតាមសមុទ្រ ជាពិសេសនៅ កុងដ័រ ដែលចូលមកធ្វើបាបយើងច្រើនលើក ច្រើនគ្រានោះ មកសុំចុះចូលនិងយើងសិន ។

គ្រាន់តែបានដំណឹងនេះភ្លាម ពីរថ្ងៃក្រោយមកមនុស្សម្នាទាំងពាន់ ៗ បានចូលសុំសំបុត្រចុះចូល ។ ពេលនោះ យើងដែលគ្មានប្រាក់បំណាច់អ្វីមួយសេនតាំងពីដើមទីមក ក៏សុំឱ្យម្នាក់ ៗ ដែលសុំចុះចូល បង់មួយពីយ៉ាស ពីព្រោះយើងត្រូវប្រើស្មៀនជិត២០នាក់ ទើបសរសេរទាន់ ។

ដោយឃើញថា ក្នុងកំឡុងតែកន្លះខែសោះ មនុស្សម្នាបានចូលមកប្រកបមុខរបរដូចធម្មតាសឹងគ្រប់កន្លែង ដូចនេះ យើងក៏ចាប់មានការទុកចិត្តលើសុទ្ធចិត្តរបស់យួនបន្តិចម្ដង ៗ ទៅដែរ ។

* * *

# ពិធីបុណ្យ
# ស្រោចស្រង់សាមគ្គីភាព

ដើម្បីរំលឹកដល់វិញ្ញាណក្ខន្ធនៃយុទ្ធជនយើង ដែលបានបូជាជីវិតដើម្បីសេរីភាព និងយុត្តិធម៌ និងបងប្អូនយើងដទៃទៀតដែលបាត់បង់ជីវិតក្នុងឆាកអន្តរកាលនេះ យើងក៏បានធ្វើបុណ្យបីថ្ងៃ បីយប់ ក្នុងបរិវេណវត្តពោធិព្រឹក្ស ហៅវត្តចាស់ ។ នៅឱកាសនោះមានប្រតិភូ យួន-ចិន ស្លៀកពាក់ជាពុទ្ធមាមកជន តាមរបៀបជាអ្នកកាន់ព្រះពុទ្ធសាសនាខាងមហាយានប្រហែលជា ៣០ញុយនាក់ ដឹកនាំដោយមេចិន និងមេយួននៅទីនោះ ដូចជាលោក ង្វៀង យ៉ាង ថាយ ហៅចីកាយ ថាយ និងអស់លោកអតីតអ្នកមុខ អ្នកការ ចិន- យួន ជាច្រើន បានមកចូលរួមក្នុងពិធីបុណ្យយើងនេះដែរ ។

នៅថ្ងៃទី ៣ មុនពេលចូលបុណ្យ លោកតា ចាច់ ហ៊ីម ដែលទើបវិលមកកាន់នាទីចាស់របស់គាត់ក្នុងវត្តវិញ ក្រោយពីបានចូលរួមក្នុងការប្រយុទ្ធមួយដ៏ឃោរឃៅនៅ ភូមិព្រែក នៅពេលថ្មី ៗ នេះមក បានឡើងធ្វើសុន្ទរកថាមួយទៅកាន់ បង ប្អូនយួនបញ្ជាក់ពីឆន្ទៈប្តូរផ្តាច់របស់យើង ចំពោះអំពើអយុត្តិធម៌ និងពីគោលបំណងរបស់យើងទៅអនាគត ។ ដើម្បីតបស្នងតាំលោកតា ចាច់ ហ៊ីម អតីតចៅសង្កាត់យួន ហៅ ឆា ហស់ បានធ្វើការផ្តេផ្តាំដល់ពលរដ្ឋយួន ឲ្យរិតទំនាក់ទំនងស្រាចស្រង់មិត្តភាពជាមួយ បង ប្អូនយើងវិញ ពីព្រោះ យួន និង ខ្មែរ ត្រូវរួមរស់ជាមួយគ្នាតទៅទៀតនៅលើដីនេះ ទោះយើងទាំងអស់គ្នា ចង់ក្តី មិនចង់ក្តី ។

⁂

# សកម្មភាព គ្គីង គ្រឿង អភិបាលស្រុកយើង

## ១-សកម្មភាពចៅហ្វាយស្រុកថ្មី

រវាងខែមីនា ១៩៤៦ លោកអភិបាលខេត្តយួនចូលមកដល់ព្រែកគយជាមួយទ័ពសម្ព័ន្ធមិត្តជាលើកដំបូង តាំងពីជប៉ុនចាញ់សង្គ្រាមទៅ គេបានលើក«បន្ទុប» ចៅដោយ ដាក់ឲ្យធ្វើជាអភិបាលស្រុកអណ្តូងទឹក ដែលមានការិយាល័យថ្មីនៅផ្សារព្រែកគយតែម្តង ៗ នៅក្នុងសន្តថារបស់គេ ដែលយើងអាចសន្និដ្ឋានបានថា ពិតមែនតែគេមិនបានយល់ស្របនឹងសកម្មភាពរបស់យើងពីប៉ុន្មានខែមុននេះក៏ដោយ ក៏គេមិនទុកថាយើងធ្វើនោះខុសទាំងអស់ដែរ ដោយនៅទីអវសាននៃសន្តថារបស់គេៗ បានបញ្ជាក់យ៉ាងច្បាស់ថា . . . . ពិតជាដើម្បីជាតិ ដើម្បីប្រទេស ៗ.

២– នៅក្នុងមុខដំណែងថ្មីនេះ ចៅហ្វាយស្រុកយើង បានតាំងមន្ត្រីសង្កាត់គ្រប់សង្កាត់ក្នុងស្រុក ដោយយើងបាន ចាត់តាំងភ្នាក់ងារសង្កាត់គ្រប់សង្កាត់ក្នុងស្រុក ដោយរើស បានតែមនុស្សដែលមានកំណើតជាខ្មែរ ៗ ពលរដ្ឋយួនព្រម ទទួលតែត្រឹមតំណែង មេភូមិ ឬ ស្មៀន ហើយសម្រាប់តែ សង្កាត់ណាដែលមានសុទ្ធតែពលរដ្ឋយួនរស់នៅ ៗ

ដើម្បីបង្ហាញនូវសុទ្ធចិត្តរបស់យើង យើងបានរិតទំប្រ មែរប្រមូលខ្មែរ និង យួនឱ្យរួមរស់ជាមួយគ្នាដូចដើម ដើម្បី បំរើកិច្ចការរួម ដោយឥតមានប្រកាន់ជាតិសាសន៍សោះ ឡើយ ៗ ក្រោយមកទៀត រដ្ឋការយួនក៏បានប្រគល់អាវុធ និង គ្រាប់រំសេវជាច្រើនមកដល់យើង ដែលយើង និង យួនបានប្រើអាវុធនោះជាមួយគ្នា ដើម្បីបង្ក្រាបអំពើចោរកម្ម ដែលមានកើតឡើង ដោយសារអ្នកទោសរត់ពីកោះត្រឡាច បង្ករបង្កើតឡើង ៗ

៣ មានការរំដោះលោកសង្ឃ និងជូនដីកាត្រលិកនៅ ភូមិជង់ក្ដាង ឱ្យចាកផុតពីក្ដីអន្តរាយ ៗ បានកំចាត់ក្រុម ចោរកំណាចមួយក្រុម នៅពេលដែលវាកំពុងចាប់កូនក្រមុំអ្នក ស្រុក និងជញ្ជូនឥវ៉ាន់ដាក់ក្នុងទូកប្រង់ឆ្លងទៅពួនតាមកោះ ក្នុងសមុទ្រ ៗ ក្រោយពីចោរកាប់ចំដោយ ជាត់ បាក់តាំភ្លើងនៅ ពេលប្រតាយប្រតប់គ្នាមក អ្នកស្រុកមួយក្រុមបានចូលជួយ

ប្រយុទ្ធ ហើយចាប់បានមេក៏យកទៅសម្លាប់ភ្លាមទៅ ។ អ្នកដែលសម្លាប់អាចោរ មានផុកខាងកញ្ញារងគ្រោះ អ្នកម្ចាស់របស់ និងក្រុមញាតិជាមួយអ្នកភូមិជងរបងជាមួយ នៅក្នុងភូមិមួយនៅជិតភូមិមាន់គោង ។

៤– រួចហើយយើងក៏ចាត់ចែងចែកអំបិល រាប់ប្រើន ៣ន់តោនសល់ពីជប៉ុន ហើយដែលជាប្រភពមួយដែរក្នុងជម្លោះរវាងយើង និង យួន ម្តងណេះដោយគ្មានប្រកាន់ពូជសាសន៍ដូចមុនៗទៀតឡើយ ។

៥- តាមការអំពាវនាវរបស់យើង ពលរដ្ឋយួន-ចិន នៅផ្សារព្រែកគយ-កូនក្អែក-បឹងព្រលិត បានរួបរួមគ្នា ជាមួយយើងដើម្បីផ្លូសផុលវត្តកូនក្អែកឡើងវិញ មិនតែប៉ុណ្ណោះ យើងបានកសាងស្ពានឈើបានពីរនិងរៀបចំផ្លូវក្បែរវត្តពោធិព្រឹក្ស ដោយយួន-ចិន គេសុខចិត្តរំលាយខ្មោចជីដូន-ជីតាគេចេញ ដើម្បីបង្ហាញការស្មោះត្រង់របស់គេមកលើប្រយោជន៍រួមផង បង្ហាញថាយើងនិងយួនល្មមជឿគ្នាវិញបានផង ។

# យោបល់រួម

ក្រោយពីបានអានអត្ថបទនេះមក អស់លោកអ្នកអាចឆ្លុះឃើញថា ខ្មែរនិងយួននៅកម្ពុជា ក្រោយដែលស្ថានភាពភូមិសាស្ត្រ បានតម្រូវឲ្យរួមរស់ជាមួយគ្នាអស់កល្បអស់កាលនោះ មានប្រយោជន៍អ្វីនឹងយកគ្នាជាសត្រូវ ? ក្នុងករណីយនេះ ប្រសិនបើអ្នករដ្ឋការនៅទីនោះ ទោះមានឋានៈទាបតូចយ៉ាងណាក្តី ព្រមធ្វើដឹង ធ្វើឃើញ នូវហេតុភេទទាំងឡាយដែលយួន បា នបង្ករមកលើពលរដ្ឋខ្មែរតាំងពីដើមទីតាំងពីមានភាពនៅជាផ្សេងនោះឡើយ ម្ល៉េះការកាប់សម្លាប់គ្នា ប្រាកដជាពុំមានកើតឡើងបានទេ។ ម្យ៉ាងទៀត ព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើងបានបញ្ជាក់ទៀតថា ជាតិសាសន៍ណាដែលមិនខ្លាចស្លាប់ ប្រាកដជារស់ នេះហើយ ជាសេចក្តីសន្និដ្ឋានរបស់យើង ។

ជាទីអវសាននៃអត្ថបទនេះ សូមបញ្ជាក់ថា យើងឃើញការរួមរស់រវាងយើង និងយួន ជាមិត្តយើងនៅកម្ពុជាក្រោមពីអតីតកាល និងនៅបច្ចុប្បន្នកាល មានភាពយ៉ាងណា ៗ នោះហើយ រីឯអនាគតកាលវិញ មានតែពេលវេលា និងប្រវត្តិសាស្ត្រទេដែលអាចបង្ហាញឲ្យយើងឃើញបាន ។ ប៉ុន្តែអ្វីដែលយើងដឹងប្រាកដ គឺស្ថានភាពភូមិសាស្ត្របានតម្រូវ និងតម្រូវទៅទៀតឲ្យយើង និងយួន ជាមិត្តយើងរស់នៅជាអ្នកភូមិផងរបងជាមួយរហូតភ្លើងឆេះកល្ប ទោះយើងចង់ក្តី មិនចង់ក្តី ។

ដូចនេះ ព្រឹត្តិការណ៍ដែលបានកន្លងទៅហើយតាំងពីឆ្នាំ ១៩៤៦ នោះត្រូវយើង និងយួន ព្រមសុខចិត្តចាត់ទុកថាជានិមិត្តដ៏អាក្រក់ទៅចុះ ហើយបន្តការរួមរស់របស់យើងតទៅទៀត ។ ដើម្បីទៅដល់គោលការណ៍នោះខ្មែរ និងយួន ត្រូវជៀសវាងអ្វីដែលម្ខាងអាចចាត់ទុកថាជាការរំលោភ អមិត្តអមនុស្សធម៌ ។ល។ ពោលគឺអ្វីដែលមិនមែនជាសញ្ញាសន្តិភាព ជាពន្លឺយុត្តិធម៌ ហើយរួមគ្នារកផ្លូវសម្របសម្រួលក្នុងគំនិតកសាងតទៅ ។

* * *

## តារាងរាយឈ្មោះជាខ្មែរ នៃខេត្ត-ស្រុក-សង្កាត់
### ពិសេសៗនៅកម្ពុជាក្រោម ដែលបានលើកយកក្នុងរឿង...
### «វស់ ព្រោះប៉ាកគូរាបំ»ហើយប្រែឈ្មោះជាយួនដល់សព្វថ្ងៃ

| ឈ្មោះដើមជាខ្មែរ | ឈ្មោះជាយួន លើកទី ១ | ឈ្មោះជាយួន ពេលថ្មីនេះ | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ខេត្តឃ្លាំង «បាសាក់» | Soctrang | Baxuyên | ខេត្តឃ្លាំង |
| — ក្រមួនស | Rachgia | Kiên Giang | |
| — ព្រះត្រពាំង | Travinh | Vinh Binh | |
| — ព្រែកឫស្សី | Cantho | Phong Dinh | |
| — ពាម បារ៉ាជ | Long Xuyen | An Giang | |
| — មាត់ ជ្រូក | Chaudoc | Chaudoc | |
| — ពល លាវ | Baclieû | Baclièn | |
| — ទួលតាមោក | Thudaumot | Binh Duong | |
| — ទឹកខ្មៅ | Camau | An Xuyen | |
| — ឫ កាប់ | Cap St Jacques | Vung Tau | |
| ស្រុក អណ្ដូងទឹក | Long Phu | Long Phu | |
| សង្កាត់ព្រែកគយ | Rachgoi | Rachgoi | |
| — ព្រែកចាក | Chac Vàng | Chac Vàng | |
| — ផ្លូវពេន | Lo Viéng | Lo Viéng | |
| — ផ្លូវកំបុត | ឥតប្រែ | ឥតកែប្រែ | |

| | | | |
|---|---|---|---|
| សង្កាត់ដង់ក្ដាន់ | Bai Gia | Bai Gia | |
| — ភូនក្អែក | Ngang Hô | Ngang Hô | |
| — ដើមពោធិ | Lam Vô | Lam Vô | |
| — ទ្វិន តាវ៉ាង | Dinh My | Dinh My | |
| — កំពង់ ឈើទាល | មិនចាំ | មិនចាំ | |
| — ដៃ ថង | Lièu Tú | Lièu Tú | |
| — បឹង ព្រលិត | Búng Lúc | Búng Lúc | |
| — តាចារ | Bàng Làng | Bàng Làng | |
| — បឹងទ្រៀក | មិនចាំ | គ្មាន | |
| — បឹងរមៀរ | Búng Sa | គ្មាន | |
| ភូមិ មាន់គោង | មិនចាំ | មិនចាំ | |
| — ទានេ ឯត្បូង | My Thanh | My Thanh | |
| — ឯ លិច | Lich Hoi Thuong | Lich Hoi Thuong | |
| — ឯ កើត | មិនចាំ | មិនចាំ | |
| — ប្រហាត | មិនចាំ | មិនចាំ | ខេត្ត ពល |
| — យ៉ា រ៉ាយ | ឥតមានប្រែ | ឥតមានកែប្រែ | |
| — ផ្ការក្រូត | Giâng Nôi | Giâng Nôi | |
| — ដាំ គិន | គ្មានឈ្មោះជាខ្មែរទេ | ជាភូមិកើតថ្មី | |
| — ដាំ យ៉ឹយ | —៨— | | |
| — ព្រែក ហូរផុង | ព្រែកហូរផុង | ព្រែកហូរផុង | |

www.ameKhmer.org